# ព្រឹទ្ធសភា

# *SENATE MAGAZINE*

ទស្សនាវដ្តីប្រចាំខែតុលា



លេខ ២៦៤ ឆ្នាំទី២២
ពុទ្ធសករាជ ២៥៦៦ គ្រិស្តសករាជ ២០២២

Issue 264 Volume 22
Before Christ 2566 Common Era 2022

# មាតិកា

## សកម្មភាពថ្នាក់ដឹកនាំ




- សម្តេចប្រធានព្រឹទ្ធសភាដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ............ ១
- សម្តេចប្រធានព្រឹទ្ធសភាបន្តដឹកនាំសម័យប្រជុំលើកទី៩ ព្រឹទ្ធសភានីតិកាលទី៤ ...... ២
- សម្តេចប្រមុខរដ្ឋស្តីទីទទួលជួបគណៈប្រតិភូគណៈកម្មការស៊ើបអង្កេត អំពើពុករលួយ ការប្រព្រឹត្តខុស និងពង្រឹងអភិបាលកិច្ចល្អ នៃព្រឹទ្ធសភាថៃ................ ៤
- សម្តេចប្រធានព្រឹទ្ធសភាទទួលជួបឯកឧត្តមនាយករដ្ឋមន្ត្រីគុយបា .......... ៧
- សម្តេចប្រធានព្រឹទ្ធសភាទទួលជួបឯកឧត្តមប្រធានាធិបតីទីម័រឡេស្តេ .......... ១០
- ថ្នាក់ដឹកនាំព្រឹទ្ធសភាជួបសំណេះសំណាលជាមួយនឹងប្រជាពលរដ្ឋ .......... ១២


## សកម្មភាពគណៈកម្មការ




- គណៈកម្មការទី១ព្រឹទ្ធសភា ក្រសួងមហាផ្ទៃ និងក្រសួងពាក់ព័ន្ធ ប្រជុំពិភាក្សាលើ សំណើរបស់ជនជាតិដើមភាគតិច .......... ១៥
- គណៈកម្មការទី១ព្រឹទ្ធសភា និងក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨ ជួបពិភាក្សាការងារជាមួយតំណាងជនជាតិដើមភាគតិច.......... ១៧
- ព្រះសង្ឃ សាស្ត្រាចារ្យ និងនិស្សិត នៃសាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច ខេត្តបាត់ដំបង ទស្សនកិច្ចសិក្សាឈ្វេងយល់អំពីព្រឹទ្ធសភា .......... ១៩
- សភាកម្ពុជារៀបចំសិក្ខាសាលាចំនួន៣ថ្ងៃស្តីពីស្វ័យភាពសេដ្ឋកិច្ចរបស់ស្ត្រី នៅតំបន់ជនបទ និងវិធីសាស្ត្រ នៃការចរចាប្រើប្រាស់នៅក្នុងក្របខ័ណ្ឌកិច្ចការសភា ..........២១
- គណៈកម្មការទី១០ព្រឹទ្ធសភាអញ្ជើញជួបពិភាក្សាការងារជាមួយគណៈប្រតិភូព្រឹទ្ធសភាថៃ ..........២៣
- គណៈកម្មការទាំង១០ព្រឹទ្ធសភាចូលរួមកិច្ចប្រជុំនានា ..........២៥
- ការងារទទួលពាក្យបណ្តឹង ..........២៨
- សមាជិក សមាជិកាព្រឹទ្ធសភាបំពេញបេសកកម្មក្រៅប្រទេស ..........២៨
- សមាជិក សមាជិកាព្រឹទ្ធសភាបំពេញការងារនៅតាមបណ្តាភូមិភាគទាំង៨..........២៩
- សមាជិក សមាជិកាព្រឹទ្ធសភាចូលរួមពិធីផ្សេងៗ ..........៤០


## សកម្មភាពអគ្គលេខាធិការដ្ឋាន





- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែកញ្ញា និងនព្វមាស ព្រមទាំងកំណត់ទិសដៅការងារបន្ត ឆ្នាំ២០២២ .......... ៤៣
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភារៀបចំពិធីសំណេះសំណាលជាមួយនិវត្តជន និងមន្ត្រីរាជការវ័យចំណាស់..........៤៤
- ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចូលរួមកិច្ចប្រជុំ និងពិធីផ្សេងៗ ..........៤៦



**អ្នកគ្រប់គ្រងទូទៅ**

ឯកឧត្តម អ៊ុំ សារិទ្ធ

**អ្នកសម្រួលខ្លឹមសារ និងអក្ខរាវិរុទ្ធ**

ឯកឧត្តម លឹម ប៊ុនហុក

ឯកឧត្តម កែវ ចាន់ណា

ឯកឧត្តម សុខ រិទ្ធី

ឯកឧត្តម ជួន ណា

ឯកឧត្តម គឹម ពិសិដ្ឋ

លោក ជួន សុខជី

លោក ទេព មករា

លោក កុក វ៉ៃ

**អ្នកគ្រប់គ្រងផ្ទាល់**

លោក ទេព មករា

**ក្រុមអ្នកយកព័ត៌មាន**

ការិយាល័យព័ត៌មាន

**ការីកុំព្យូទ័រ**

លោក ជុំ ច័ន្ទរតនា

លោកស្រី សុខ សុជាតា


*ក្របមុខ ៖ សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា អញ្ជើញថតរូបអនុស្សាវរីយ៍ជាមួយឯកឧត្តម ម៉ានូអែល ម៉ារ៉េរ៉ូ គ្រូស នាយករដ្ឋមន្ត្រី នៃសាធារណរដ្ឋគុយបា។*

*ក្របក្រោយ ៖ សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា អញ្ជើញថតរូបអនុស្សាវរីយ៍ជាមួយគណៈប្រតិភូជាន់ខ្ពស់ នៃសាធារណរដ្ឋប្រជាធិបតេយ្យទីម័រឡេស្តេ៕*


**អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា**

**វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា**

**ទូរស័ព្ទ: (855) 23 211441, 211442, 211443, ទូរសារ: (855) 23 211446**

**E-mail : oumsarith.sgsenate@gmail.com**

**Website: www.senate.gov.kh**

**www.elibrary.senate.gov.kh**

**Facebook: www.facebook.com/senateofcambodia**

# សម្ដេចប្រធានព្រឹទ្ធសភា ដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា



*សម្ដេចវិបុលសេនាភក្ដី សាយ ឈុំ អញ្ជើញដឹកនាំកិច្ចប្រជុំ គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា*

នាថ្ងៃចន្ទ ទី១០ ខែតុលា ឆ្នាំ២០២២ វេលាម៉ោង៨:០០ នាទីព្រឹក គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា បានប្រជុំក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិនិត្យសម្រេចលើរបៀបវារៈចំនួន២ ដូចខាងក្រោម៖

**១-ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការផែនការ វិនិយោគ កសិកម្ម ធនធានទឹក ឧតុនិយម អភិវឌ្ឍន៍ជនបទ និងបរិស្ថាន សុំដាក់សេចក្ដីព្រាងច្បាប់ស្ដីពីការអនុម័តយល់ព្រមលើពិធីសារទីបួន ស្ដីពីវិសោធនកម្មកិច្ចព្រមព្រៀងវិនិយោគទូលំទូលាយអាស៊ានទៅក្នុងរបៀបវារៈសម័យប្រជុំលើកទី៩ ព្រឹទ្ធសភានីតិកាលទី៤។**

**២-កំណត់របៀបវារៈ និងកាលបរិច្ឆេទបន្តសម័យប្រជុំលើកទី៩ ព្រឹទ្ធសភានីតិកាលទី៤។**

បន្ទាប់ពីបានពិនិត្យ និងពិភាក្សារួចមក គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាបានកំណត់យកថ្ងៃអង្គារ ទី១១ ខែតុលា ឆ្នាំ២០២២ វេលាម៉ោង៨:០០នាទីព្រឹក បន្តសម័យប្រជុំលើកទី៩ ព្រឹទ្ធសភានីតិកាលទី៤ ដើម្បីពិនិត្យ ហើយឱ្យយោបល់លើសេចក្ដីព្រាងច្បាប់ស្ដីពី ការអនុម័តយល់ព្រមលើពិធីសារទីបួន ស្ដីពីវិសោធនកម្មកិច្ចព្រមព្រៀងវិនិយោគទូលំទូលាយអាស៊ាន។៚

(អត្ថបទ៖ នុត សច្ចៈ រូបភាព៖ គង់ យ៉ារីន)



*ឯកឧត្តមបណ្ឌិត ម៉ុង ឫទ្ធី អញ្ជើញអានរបាយការណ៍ក្នុងកិច្ចប្រជុំ*



*ទិដ្ឋភាពកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា*

# សម្ដេចប្រធានព្រឹទ្ធសភាបន្តដឹកនាំសម័យប្រជុំ លើកទី៩ ព្រឹទ្ធសភា នីតិកាលទី៤



*សម្ដេចវិបុលសេនាភក្ដី សាយ ឈុំ ដឹកនាំបន្តសម័យប្រជុំ លើកទី៩ ព្រឹទ្ធសភា នីតិកាលទី៤*

នាព្រឹកថ្ងៃអង្គារ ទី១១ ខែតុលា ឆ្នាំ២០២២ វេលាម៉ោង ៨:០០នាទី ព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានបន្តសម័យប្រជុំលើកទី៩ នីតិកាលទី៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ដោយមានសមាជិកព្រឹទ្ធសភាចូលរួមចំនួន៥៥រូប ដើម្បីពិនិត្យ ហើយឱ្យយោបល់លើសេចក្ដីព្រាងច្បាប់ស្ដីពី ការអនុម័តយល់ព្រមលើពិធីសារទីបួន ស្ដីពីវិសោធនកម្មកិច្ចព្រមព្រៀងវិនិយោគទូលំទូលាយអាស៊ាន ។

នៅក្នុងឱកាសនោះ ឯកឧត្ដមបណ្ឌិត **ម៉ុង ឫទ្ធី** ប្រធានគណៈកម្មការទី៣ព្រឹទ្ធសភា បានអញ្ជើញឡើងធ្វើសេចក្ដីរាយការណ៍ជូនអង្គប្រជុំបានជ្រាបអំពីលទ្ធផល នៃការពិនិត្យសិក្សាលើសេចក្ដីព្រាងច្បាប់ស្ដីពី ការអនុម័តយល់ព្រមលើពិធីសារទីបួន ស្ដីពីវិសោធនកម្មកិច្ចព្រមព្រៀងវិនិយោគទូលំទូលាយអាស៊ានថា សេចក្ដីព្រាងច្បាប់នេះមានគោលបំណងសំខាន់ជំរុញរំហូរវិនិយោគក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ាន និងបង្កើតបរិយាកាសវិនិយោគដោយសេរី ងាយស្រួល មានតម្លាភាព និងមានលក្ខណៈប្រកួតប្រជែង ដើម្បីផ្ដល់អត្ថប្រយោជន៍ដល់វិនិយោគិន និងការវិនិយោគក្នុងអាស៊ាន ព្រមទាំងមានភាពចាំបាច់សម្រាប់ធ្វើការវាយតម្លៃ និងត្រួតពិនិត្យឡើងវិញនូវលក្ខខណ្ឌតម្រូវកាតព្វកិច្ចចំពោះវិនិយោគិនបរទេសដែលនៅជាធរមានរបស់រដ្ឋសមាជិក និងពិចារណាធ្វើការប្ដេជ្ញាចិត្តបន្ថែមនៅក្នុងមាត្រា៧ (ការហាមឃាត់លក្ខខណ្ឌតម្រូវឱ្យបំពេញកាតព្វកិច្ច) នៃកិច្ចព្រមព្រៀងវិនិយោគទូលំទូលាយអាស៊ាន ដើម្បីធ្វើឱ្យកិច្ចព្រមព្រៀងកាន់តែប្រសើរឡើង និងអំណោយផលដល់ការទាក់ទាញវិនិយោគពីប្រទេសផ្សេងៗមកក្នុងតំបន់អាស៊ាន។

ពិធីសារទីបួននេះ នឹងក្លាយជាលិខិតូបករណ៍អន្តរជាតិមួយទៀត ដែលជួយឱ្យព្រះរាជាណាចក្រកម្ពុជាក្នុងការទាក់ទាញក្រុមហ៊ុនដែលចុះបញ្ជីនៅក្នុងបណ្ដារដ្ឋសមាជិកអាស៊ាន មកបណ្ដាក់ទុនវិនិយោគនៅព្រះរាជាណាចក្រ-



*ទិដ្ឋភាពបន្តសម័យប្រជុំលើកទី៩ ព្រឹទ្ធសភានីតិកាលទី៤*



*ឯកឧត្តមបណ្ឌិត ម៉ុង ឫទ្ធី ឡើងអានរបាយការណ៍ជូនអង្គប្រជុំ*



*ឯកឧត្តម ជិន ប៊ុនស៊ាន ឡើងស្រាយបំភ្លឺជូនអង្គប្រជុំព្រឹទ្ធសភា*

កម្ពុជាប្រកបដោយភាពជឿជាក់លើរាជរដ្ឋាភិបាលកម្ពុជា។

បន្ទាប់ពីសមាជិកព្រឹទ្ធសភាចំនួន៤រូប បានឡើងមានយោបល់ និងលើកជាសំណួរ សំណូមពរសុំការបំភ្លឺរួចមក ឯកឧត្តម **ជិន ប៊ុនស៊ាន** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស និងជាអនុប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងឯកឧត្តម **សុខ ចិន្ដាសោភា** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាអគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានឡើងស្រាយបំភ្លឺជូនអង្គប្រជុំព្រឹទ្ធសភា។

អង្គប្រជុំព្រឹទ្ធសភាបានពិនិត្យ ហើយឱ្យយោបល់ឯកភាពទាំងស្រុងលើសេចក្ដីព្រាងច្បាប់ទាំងមូល ដោយឥតកែប្រែ ចំនួន៥៥សំឡេង នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល។

សូមជម្រាបថា សេចក្ដីព្រាងច្បាប់នេះតាក់តែងឡើងមាន២មាត្រា ត្រូវបានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា



*ឯកឧត្តម សុខ ចិន្ដាសោភា ឡើងស្រាយបំភ្លឺជូនអង្គប្រជុំព្រឹទ្ធសភា*

អនុម័តយល់ព្រមជាលើកដំបូងចំនួន៩៦សំឡេង នៃចំនួនសមាជិករដ្ឋសភាទាំងមូល កាលពីថ្ងៃទី៣ ខែតុលា ឆ្នាំ ២០២២ នាសម័យប្រជុំរដ្ឋសភាលើកទី៨ នីតិកាលទី៦៕

(អត្ថបទ៖ អ៊ុក ប៉ូលីន រូបភាព៖ គង់ យ៉ារីន)





*ទិដ្ឋភាពសមាជិក សមាជិកាព្រឹទ្ធសភា លើកដៃអនុម័តលើសេចក្ដីព្រាងច្បាប់*

# សម្តេចប្រមុខរដ្ឋស្តីទីទទួលជួបគណៈប្រតិភូគណៈកម្មការស៊ើបអង្កេត អំពើពុករលួយ ការប្រព្រឹត្តខុស និងពង្រឹងអភិបាលកិច្ចល្អ នៃព្រឹទ្ធសភាថៃ



*ឧត្តមនាវីឯក សិសថាវ៉ាត វង្សសុវណ្ណ និងសម្តេចវិបុលសេនាភក្តី សាយ  ឈុំ*

នាព្រឹកថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២២ វេលាម៉ោង៩:០០ នាទី នៅវិមានព្រឹទ្ធសភា សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រមុខរដ្ឋស្តីទី នៃព្រះរាជាណាចក្រកម្ពុជា បានអនុញ្ញាតឱ្យគណៈប្រតិភូគណៈកម្មការស៊ើបអង្កេតអំពើពុករលួយ ការប្រព្រឹត្តខុស និងពង្រឹងអភិបាលកិច្ចល្អ នៃព្រឹទ្ធសភា នៃព្រះរាជាណាចក្រថៃឡង់ដ៍ ដឹកនាំដោយឯកឧត្តមឧត្តមនាវីឯក **សិសថាវ៉ាត វង្សសុវណ្ណ** ប្រធានគណៈកម្មការ ចូលជួបសម្តែងការគួរសម ក្នុងឱកាសអញ្ជើញមកបំពេញទស្សនកិច្ចសិក្សាឈ្វេងយល់អំពី ការប្រយុទ្ធប្រឆាំងអំពើពុករលួយនៅព្រះរាជាណាចក្រកម្ពុជា។

ក្នុងព្រះបរមនាមព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និងក្នុងនាមសម្តេចផ្ទាល់ សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** បានសម្តែងនូវការស្វាគមន៍យ៉ាងកក់ក្តៅចំពោះគណៈប្រតិភូ ដែលបានអញ្ជើញមកបំពេញទស្សនកិច្ចនៅព្រះរាជាណាចក្រកម្ពុជា។ សម្តេចជឿជាក់ថា ដំណើរទស្សនកិច្ចរបស់គណៈប្រតិភូនៅកម្ពុជានាឱកាសនេះ ពិតជាបានរួមចំណែកដ៏សំខាន់ដល់ការពង្រឹងពង្រីកទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរឱ្យកាន់តែល្អប្រសើរជាងមុនថែមទៀត ដើម្បីជាគុណប្រយោជន៍ដ៏ធំធេងសម្រាប់ប្រជាជន និងប្រទេសទាំងពីរ ទាំងពេលបច្ចុប្បន្ន និងពេលអនាគត។

ក្នុងឱកាសនោះ ឯកឧត្តមឧត្តមនាវីឯក **សិសថាវ៉ាត វង្សសុវណ្ណ** បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះសម្តេចប្រមុខរដ្ឋស្តីទី ដែលបានចំណាយពេលដ៏មានតម្លៃទទួលស្វាគមន៍គណៈប្រតិភូយ៉ាងកក់ក្តៅ។ ឯកឧត្តមឧត្តមនាវីឯកបានចាត់ទុកដំណើរទស្សនកិច្ចរបស់គណៈប្រតិភូនៅព្រះរាជាណាចក្រកម្ពុជា គឺជាការពង្រឹងពង្រីកទំនាក់-





*ទិដ្ឋភាពក្នុងពិធីជួបសម្តែងការគួរសម*



*ទិដ្ឋភាពក្នុងពិធីជួបសម្តែងការគួរសម*

ទំនងកិច្ចសហប្រតិបត្តិការ និងការផ្លាស់ប្តូរបទពិសោធន៍ឈ្វេងយល់គ្នាទៅវិញទៅមក ដើម្បីលើកកម្ពស់កិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរឱ្យកាន់តែជិតស្និទ្ធបន្ថែមទៀត។

ឯកឧត្តមឧត្តមនាវីឯក **សិសថាវ៉ាត វងុ្សសុវណ្ណ** បានជម្រាបជូនសម្តេចប្រមុខរដ្ឋស្តីទីជ្រាបថា ដំណើរទស្សនកិច្ចរបស់គណៈប្រតិភូគឺមានគោលបំណងដើម្បីសិក្សាឈ្វេងយល់អំពីការងារប្រឆាំងអំពើពុករលួយ។ ឯកឧត្តមឧត្តមនាវីឯកសង្ឃឹមថាសភា នៃប្រទេសទាំងពីរនឹងមានកិច្ចសហប្រតិបត្តិការជាមួយគ្នាទៅលើវិស័យនេះ។

ឯកឧត្តមឧត្តមនាវីឯក **សិសថាវ៉ាត វងុ្សសុវណ្ណ** បានបញ្ជាក់ថា ព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រថៃឡង់ដ៍មានព្រំប្រទល់ជាប់គ្នា ប្រជាជនមានទំនាក់ទំនងយ៉ាងជិតស្និទ្ធ មានវប្បធម៌ ទំនៀមទម្លាប់ប្រពៃណីស្រដៀងគ្នា ជាពិសេសប្រជាជនរស់នៅតាមបណ្តោយព្រំដែនតែងតែមានការពឹងពាក់យកអាសាគ្នាទៅវិញទៅមកតាំងពីយូរលង់ណាស់មកហើយ។ ជាមួយគ្នានេះ ប្រទេសទាំងពីរជាប្រទេសសមាជិកអាស៊ាន ដែលមានទំនាក់ទំនងជាមួយគ្នាលើគ្រប់វិស័យ ប្រៀបដូចជាគ្រួសារតែមួយ។ ក្នុងនោះ ស្ថាប័ននីតិប្បញ្ញត្តិ នៃប្រទេសទាំងពីរ បានដើរតួជាយន្តការដ៏សំខាន់ក្នុងការពង្រឹងពង្រីកទំនាក់ទំនងមិត្តភាព និងលើកកម្ពស់កិច្ចសហប្រតិបត្តិការលើគ្រប់វិស័យ ដើម្បីនាំមកនូវសន្តិសុខជូនប្រទេសជាតិ ដែលជាប្រយោជន៍ដ៏ខ្ពង់ខ្ពស់បំផុតចំពោះប្រទេសទាំងពីរ។

សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** បានរំលឹកថា ព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រថៃឡង់ដ៍ បានភ្ជាប់ទំនាក់ទំនងការទូតជាផ្លូវការចាប់តាំងពីឆ្នាំ១៩៥០ ដែលគិតមកដល់ពេលបច្ចុប្បន្ននេះ គឺមានរយៈពេល៧២ឆ្នាំមកហើយ។ សម្តេចបានសម្តែងនូវសេចក្តីរីករាយដោយមើលឃើញនូវទំនាក់ទំនងមិត្តភាព និងកិច្ចសហប្រតិបត្តិការ នៃប្រទេសទាំងពីរមានការរីកចម្រើនជាលំដាប់។ ការរីកចម្រើននេះស្តែងឡើងតាមរយៈការផ្លាស់ប្តូរទស្សនកិច្ចគ្នាទៅវិញទៅមករវាងថ្នាក់ដឹកនាំ និងមន្ត្រីជាន់ខ្ពស់ នៃប្រទេសទាំងពីរ។

សម្តេចប្រមុខរដ្ឋស្តីទីបានបញ្ជាក់ថា ទោះបីប្រទេសទាំងពីរបាននឹងកំពុងប្រឈមទៅនឹងការរាតត្បាតជំងឺកូវីដ-១៩ យ៉ាងណាក្តី ក៏ប៉ុន្តែប្រទេសទាំងពីរនៅតែបានជួយគ្នាទៅវិញទៅមក ក្នុងនាមជាបងប្អូន និងជាអ្នកជិតខាងល្អ។ ជាមួយគ្នានោះ សម្តេចបានថ្លែងអំណរគុណដល់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រថៃឡង់ដ៍ ដែលបានផ្តល់ជំនួយដល់

រាជរដ្ឋាភិបាលកម្ពុជា ក្នុងយុទ្ធនាការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ និងគ្រោះទឹកជំនន់កាលពីឆ្នាំ២០២០កន្លងទៅ ការងារក្នុងប្រទេសថៃ ការជួយតបណ្តាញអគ្គិសនី និងការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធជាដើម។

សម្តេចប្រមុខរដ្ឋស្តីទីបានវាយតម្លៃខ្ពស់ ចំពោះការបន្តរីកចម្រើនជាលំដាប់ នៃទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការល្អរវាងសភា នៃប្រទេសទាំងពីរ ដែលត្រូវបានលើកកម្ពស់ឥតឈប់ឈរ និងមានការគាំទ្រគ្នាទៅវិញទៅមកក្នុងក្របខ័ណ្ឌទ្វេភាគី និងពហុភាគី ដែលតែងតែជួយគាំទ្រគ្នាទៅវិញទៅមកលើឆាកអន្តរជាតិ មិនត្រឹមតែទទួលបានផលប្រយោជន៍សម្រាប់ប្រទេសទាំងពីរប៉ុណ្ណោះទេ ប៉ុន្តែបានរួមចំណែកជាវិភាគទានដល់ការថែរក្សាសន្តិភាព ស្ថិរភាព សន្តិសុខ និងការអភិវឌ្ឍនៅក្នុងតំបន់ និងសកលលោកផងដែរ។

សម្តេចប្រមុខរដ្ឋស្តីទីបានបញ្ជាក់ថា ក្នុងនាមជាប្រធានអាស៊ានប្តូរវេន សភាកម្ពុជានឹងធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំមហាសន្និបាតអន្តរសភាអាស៊ានលើកទី៤៣ នៅក្នុងខែវិច្ឆិកាខាងមុខនេះ ក្រោមមូលបទ “ឆ្ពោះទៅមុខរួមគ្នាដើម្បីអាស៊ាន ប្រកបដោយបរិយាបន្ន និងភាពធន់”។ ក្នុងនាមសភាកម្ពុជា សម្តេចបានអញ្ជើញសភា នៃព្រះរាជាណាចក្រថៃឡង់ដ៍ ចូលរួមកិច្ចប្រជុំនេះ ដើម្បីរួមពិភាក្សាគ្នាលើប្រធានបទសំខាន់ៗនៃមហាសន្និបាតបានដាក់ចុះ ដើម្បីរួមចំណែកដល់ការដោះស្រាយបញ្ហានានា ដែលបាននឹងកំពុងកើតឡើងក្នុងតំបន់ និងពិភពលោក។ ព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល ក្រសួង និងស្ថាប័នជាតិ នៃព្រះរាជាណាចក្រកម្ពុជា ត្រៀមខ្លួនជានិច្ច ដើម្បីធ្វើកិច្ចសហប្រតិបត្តិការដ៏ជិតស្និទ្ធជាមួយនឹងព្រះរាជាណាចក្រថៃឡង់ដ៍។

តាមរយៈគណៈប្រតិភូ សម្តេចប្រមុខរដ្ឋស្តីទីបានពាំនាំនូវព្រះរាជបណ្តាំសួរសុខទុក្ខ ដោយសេចក្តីគោរព និងនឹករលឹកពីព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ និងថ្នាក់ដឹកនាំនៃព្រះរាជាណាចក្រកម្ពុជា ថ្វាយព្រះបាទមហា **វ៉ាជីរ៉ាឡុងកន ព្រះវ៉ាជីរ៉ាក់ក្លៅចៅយូហួរ** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រថៃឡង់ដ៍ និងជូនថ្នាក់ដឹកនាំកំពូលគ្រប់លំដាប់ថ្នាក់ នៃព្រះរាជាណាចក្រថៃឡង់ដ៍។ សម្តេចបានប្រសិទ្ធពរគណៈប្រតិភូ សូមមានសុខភាពល្អ និងបំពេញទស្សនកិច្ចនៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជាបានប្រកបដោយជោគជ័យ៕

(អត្ថបទ៖ នុត សច្ចៈ រូបភាព៖ គង់ យ៉ារីន)



*សម្តេចប្រមុខរដ្ឋស្តីទី ថតរូបអនុស្សាវរីយ៍ជាមួយគណៈប្រតិភូព្រឹទ្ធសភាថៃ*

# សម្ដេចប្រធានព្រឹទ្ធសភាទទួលជួបឯកឧត្ដមនាយករដ្ឋមន្ត្រីគុយបា




*ឯកឧត្ដម ម៉ានូអែល ម៉ារ៉េរ៉ូ គ្រុស និងសម្ដេចវិបុលសេនាភក្ដី សាយ ឈុំ*

នាថ្ងៃទី៥ ខែតុលា ឆ្នាំ២០២២ វេលាម៉ោង៩:៣០នាទីព្រឹក នៅវិមានព្រឹទ្ធសភា សម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានទទួលជួបសវនាការជាមួយនឹងឯកឧត្ដម **ម៉ានូអែល ម៉ារ៉េរ៉ូ គ្រុស** (Manuel Marrero Cruz) នាយករដ្ឋមន្ត្រី នៃសាធារណរដ្ឋគុយបា ក្នុងឱកាសដែលឯកឧត្ដមដឹកនាំគណៈប្រតិភូមកបំពេញទស្សនកិច្ចជាមិត្តភាព និងផ្លូវការ នៅព្រះរាជាណាចក្រកម្ពុជា។

ក្នុងនាមប្រជាជនកម្ពុជា ព្រឹទ្ធសភាកម្ពុជា និងខ្លួនសម្ដេចផ្ទាល់ សម្ដេចប្រធានព្រឹទ្ធសភាបានសម្ដែងការស្វាគមន៍ដ៏កក់ក្ដៅចំពោះឯកឧត្ដម **ម៉ានូអែល ម៉ារ៉េរ៉ូ គ្រុស** និងគណៈប្រតិភូ ដែលបានអញ្ជើញមកបំពេញទស្សនកិច្ចជាមិត្តភាព និងផ្លូវការ នៅព្រះរាជាណាចក្រកម្ពុជា។ តាមរយៈដំណើរទស្សនកិច្ចរបស់ឯកឧត្ដមនៅកម្ពុជានាពេលនេះ ពិតជាមានសារៈសំខាន់ជាខ្លាំងដល់ការពង្រឹងពង្រីកចំណងមិត្តភាព និងកិច្ចសហប្រតិបត្តិការល្អរវាងប្រជាជន និងប្រទេសទាំងពីរឱ្យកាន់តែល្អប្រសើរឡើង និងរឹងមាំថែមទៀត ដែលនឹងនាំមកនូវផលប្រយោជន៍ដ៏ធំធេងទៅវិញទៅមក ទាំងពេលបច្ចុប្បន្ន និងពេលអនាគត។ ជាមួយគ្នានោះ សម្ដេចប្រធានព្រឹទ្ធសភាបានសម្ដែងនូវការចូលរួមសោកស្ដាយចំពោះរដ្ឋាភិបាល និងប្រជាជនគុយបា ដែលទទួលរងគ្រោះមហន្តរាយខូចខាតដោយព្យុះសង្ឃរា Hurricane Ian កាលពីសប្ដាហ៍មុន។

ក្នុងឱកាសនោះ ឯកឧត្ដម **ម៉ានូអែល ម៉ារ៉េរ៉ូ គ្រុស**




*ទិដ្ឋភាពក្នុងពិធីជំនួបសម្ដែងការគួរសម*



*ទិដ្ឋភាពក្នុងពិធីជំនួបសម្តែងការគួរសម*

បានរំលឹកអំពីទំនាក់ទំនង និងកិច្ចសហប្រតិបត្តិដ៏ល្អរវាងប្រទេសទាំងពីរតាំងពីឆ្នាំ១៩៥៩មក ជាពិសេសទំនាក់-ទំនងដ៏ល្អប្រពៃរវាងថ្នាក់ដឹកនាំគុយបា និងសម្តេចព្រះបរម-រតនកោដ្ឋ។ ក្រៅពីនេះ ប្រទេសទាំងពីរក៏មានទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការដ៏ល្អរវាងសភា នៃប្រទេសទាំងពីរផងដែរ។ នាពេលថ្មីៗនេះផងដែរ សម្តេចអគ្គមហាសេនា-បតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណា-ចក្រកម្ពុជា បានអញ្ជើញបំពេញទស្សនកិច្ចជាផ្លូវការនៅសាធារណរដ្ឋគុយបា ហើយដំណើរទស្សនកិច្ចរបស់គណៈ-ប្រតិភូនៅព្រះរាជាណាចក្រកម្ពុជានាឱកាសនេះ គឺជាសក្ខី-ភាព នៃការលើកកម្ពស់ទំនាក់ទំនងប្រទេសទាំងពីរឱ្យកាន់តែរឹងមាំថែមទៀត។

ឯកឧត្តមនាយករដ្ឋមន្ត្រី បានជម្រាបជូនសម្តេចប្រធានព្រឹទ្ធសភាជ្រាបថា គោលបំណងនៃដំណើរទស្សនកិច្ចរបស់គណៈប្រតិភូ គឺដើម្បីពង្រឹងពង្រីកនូវទំនាក់ទំនងមិត្តភាព និងកិច្ចសហប្រតិបត្តិការឱ្យកាន់តែរឹងមាំថែមទៀត ជាពិសេសការផ្សារភ្ជាប់ទំនាក់ទំនងខាងសេដ្ឋកិច្ច និងពាណិជ្ជ-កម្ម។

ឯកឧត្តមនាយករដ្ឋមន្ត្រីបានថ្លែងអំណរគុណដល់ព្រះ-រាជាណាចក្រកម្ពុជា ដែលបានផ្តល់ជំនួយជាអង្ករជូនចំពោះរដ្ឋាភិបាល និងប្រជាជនគុយបា។ តាមរយៈដំណើរទស្សន-កិច្ចនេះ ពិតជាមានសារៈសំខាន់ណាស់ក្នុងការពង្រឹងពង្រីកទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ ជាពិសេសការផ្សារភ្ជាប់ពាណិជ្ជកម្ម នៃប្រទេសទាំងពីរ ដែលអាចរួមចំណែកដល់ការអភិវឌ្ឍប្រទេសគុយបានាពេលខាងមុខ។ ជាមួយគ្នានោះ ឯកឧត្តមនាយករដ្ឋមន្ត្រីគុយបាបានសន្យាថា នឹងខិតខំប្រឹងប្រែងឱ្យអស់ពីកម្លាំងកាយចិត្ត ដើម្បីពង្រឹងពង្រីកនូវទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរឱ្យកាន់តែរឹងមាំថែមទៀត។

សម្តេចប្រធានព្រឹទ្ធសភាបានរំលឹកអំពីទំនាក់ទំនងការទូតរវាងប្រទេសទាំងពីរ ដែលត្រូវបានបង្កើតឡើងចាប់តាំងពីឆ្នាំ១៩៦០ ដោយព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះបរមរតនកោដ្ឋ និងឯកឧត្តម**ហ្វីដែល កាស្ត្រូ** ប្រធានក្រុមប្រឹក្សារដ្ឋ នៃសាធារណរដ្ឋគុយបា។ ប្រទេសទាំងពីរបានផ្លាស់ប្តូរដំណើរទស្សនកិច្ចរបស់ថ្នាក់ដឹកនាំទៅវិញទៅមក និងគាំទ្រគ្នាទាំងក្នុងក្របខ័ណ្ឌទ្វេភាគី និងពហុភាគី។ សាធារណរដ្ឋគុយបាបានគាំទ្រខាងនយោបាយ វិស័យអប់រំ និងវិស័យសុខាភិបាលដល់ប្រទេសកម្ពុជានៅក្នុងកាលៈទេសៈលំបាកបំផុត ក្រោយពីរបបប្រល័យពូជ-សាសន៍ **ប៉ុល ពត** និងក្រោមការហ៊ុមព័ទ្ធនៃសេដ្ឋកិច្ច និងនយោបាយពីខាងក្រៅ។ ប្រទេសកម្ពុជាក៏បានគាំទ្រប្រទេសគុយបាក្នុងការប្រឆាំងចំពោះការហ៊ុមព័ទ្ធសេដ្ឋកិច្ចប្រទេស

គុយបា តាមរយៈការដាក់ទណ្ឌកម្មនានាដ៏អយុត្តិធម៌ ដែលនេះបញ្ជាក់អំពីការរំលោភសិទ្ធិរបស់ប្រជាជនគុយបា និងរំលោភលើច្បាប់អន្តរជាតិ។ ការជួយគាំទ្រគ្នាទៅវិញទៅមកនេះ មិនត្រឹមតែនាំមកនូវផលប្រយោជន៍ជូនប្រទេសទាំងពីរប៉ុណ្ណោះទេ ប៉ុន្តែបានរួមចំណែកក្នុងការថែរក្សាសន្តិភាព ស្ថិរភាព សន្តិសុខក្នុងតំបន់ និងអន្តរជាតិផងដែរ។

ក្នុងនាមព្រឹទ្ធសភា និងក្នុងនាមសម្តេចផ្ទាល់ សម្តេចប្រធានព្រឹទ្ធសភាបានគាំទ្រឱ្យរដ្ឋាភិបាល នៃប្រទេសទាំងពីរបន្តអនុវត្តនូវយន្តការដែលមានស្រាប់ តាមរយៈកិច្ចប្រជុំពិគ្រោះយោបល់ និងអនុវត្តឱ្យបានពេញលេញនូវអនុស្សរណៈ នៃការយោគយល់គ្នា និងកិច្ចព្រមព្រៀងរវាងប្រទេសទាំងពីរឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់។ សម្តេចយល់ថា ប្រទេសទាំងពីរគួរតែប្រឹងប្រែងខិតខំទាញយកផលប្រយោជន៍ពីសក្តានុពល នៃយន្តការ និងកិច្ចព្រមព្រៀងខាងលើឱ្យបានច្រើនជាអតិបរមា ដើម្បីនាំមកនូវផលប្រយោជន៍ដ៏ធំធេងទៅវិញទៅមកសម្រាប់ប្រជាជន និងប្រទេសទាំងពីរ។

សម្តេចប្រធានព្រឹទ្ធសភាបានវាយតម្លៃខ្ពស់ចំពោះទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការល្អរវាងស្ថាប័ននីតិបញ្ញត្តិប្រទេសទាំងពីរ តាមរយៈការផ្លាស់ប្តូរទស្សនកិច្ច និងជំនួបរវាងថ្នាក់ដឹកនាំ និងសមាជិកសភា នៃសភាប្រទេសទាំងពីរ និងការគាំទ្រគ្នាទៅវិញទៅមកនៅក្នុងក្របខ័ណ្ឌអន្តរសភា រួមមាន៖ សន្និសីទតំបន់អាស៊ី-ប៉ាស៊ីហ្វិក (ICAP) និងសហភាពអន្តរសភា (IPU)។ តាមរយៈ ឯកឧត្តមនាយករដ្ឋមន្ត្រីគុយបា សម្តេចមានបំណងបង្កើនកិច្ចសហប្រតិបត្តិការរវាងព្រឹទ្ធសភាកម្ពុជាជាមួយនឹងរដ្ឋសភាអំណាចប្រជាជនគុយបា។

សម្តេចប្រធានព្រឹទ្ធសភាបានសម្តែងនូវការកោតសរសើរ និងអបអរសាទរចំពោះសមិទ្ធផលដ៏ធំធេងទាំងឡាយ ដែលរដ្ឋាភិបាល និងប្រជាជនគុយបាសម្រេចបានក្នុងការអភិវឌ្ឍប្រទេសជាតិ និងបានប្រសិទ្ធពរជូនប្រជាជន និងសាធារណរដ្ឋគុយបាបន្តរីកចម្រើនកាន់តែខ្លាំងក្លាថែមទៀត ដើម្បីរួមចំណែកដល់វឌ្ឍនភាព វិបុលភាព និងការអភិវឌ្ឍនៅក្នុងតំបន់។

តាមរយៈឯកឧត្តមនាយករដ្ឋមន្ត្រីគុយបា សម្តេចប្រធានព្រឹទ្ធសភាក៏បានផ្តាំផ្ញើនូវការសួរសុខទុក្ខដោយសេចក្តីគោរពរាប់អានដ៏ខ្ពង់ខ្ពស់ ជូនចំពោះឯកឧត្តមប្រធានរដ្ឋសភាអំណាចប្រជាជនគុយបា និងថ្នាក់ដឹកនាំកំពូល នៃសាធារណរដ្ឋគុយបាទាំងអស់។ សម្តេចបានប្រសិទ្ធពរជូនឯកឧត្តមនាយករដ្ឋមន្ត្រី និងគណៈប្រតិភូគុយបា សូមមានសុខភាពល្អ ទទួលបានជោគជ័យគ្រប់ភារកិច្ច ព្រមទាំងទទួលបាននូវភាពរីករាយក្នុងឱកាសស្នាក់នៅលើទឹកដី នៃព្រះរាជាណាចក្រកម្ពុជា៕

(អត្ថបទ៖ នុត សច្ចៈ រូបភាព៖ គង់ យ៉ារីន)



*សម្តេចប្រធានព្រឹទ្ធសភា ថតរូបអនុស្សាវរីយ៍ជាមួយគណៈប្រតិភូជាន់ខ្ពស់នៃសាធារណរដ្ឋគុយបា*

# សម្តេចប្រធានព្រឹទ្ធសភាទទួលជួបឯកឧត្តមប្រធានាធិបតីទីម័រឡេស្តេ



*ឯកឧត្តម ចូហ្សេ រ៉ាម៉ូស ហរតា និងសម្តេចវិបុលសេនាភក្តី សាយ ឈុំ*

នារសៀលថ្ងៃទី២០ ខែតុលា ឆ្នាំ២០២២ វេលាម៉ោង ១៤:១០នាទី នៅវិមានព្រឹទ្ធសភា សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានទទួលជួបសវនាការជាមួយនឹងឯកឧត្តមបណ្ឌិត **ចូហ្សេ រ៉ាម៉ូស ហរតា** (Jose Ramos-Horta) ប្រធានាធិបតី នៃសាធារណរដ្ឋប្រជាធិបតេយ្យទីម័រឡេស្តេ ក្នុងឱកាសដែលឯកឧត្តមដឹកនាំគណៈប្រតិភូជាន់ខ្ពស់ អញ្ជើញមកបំពេញទស្សនកិច្ចផ្លូវរដ្ឋ នៅព្រះរាជាណាចក្រកម្ពុជា។

ក្នុងនាមព្រឹទ្ធសភា និងក្នុងនាមសម្តេចផ្ទាល់ សម្តេចប្រធានព្រឹទ្ធសភាបានសម្តែងនូវការស្វាគមន៍ដ៏កក់ក្តៅចំពោះឯកឧត្តមប្រធានាធិបតី ដែលបានដឹកនាំគណៈប្រតិភូជាន់ខ្ពស់ នៃសាធារណរដ្ឋប្រជាធិបតេយ្យទីម័រឡេស្តេ មកបំពេញទស្សនកិច្ចផ្លូវរដ្ឋ នៅព្រះរាជាណាចក្រកម្ពុជា។ តាមរយៈដំណើរទស្សនកិច្ចរបស់គណៈប្រតិភូ ពិតជាមានសារៈសំខាន់ដល់ការពង្រឹងពង្រីកនូវទំនាក់ទំនងមិត្តភាព និងកិច្ចសហប្រតិបត្តិការរវាងប្រជាជន និងប្រទេសទាំងពីរឱ្យកាន់តែរីកចម្រើនថែមទៀត ដើម្បីជាគុណប្រយោជន៍ដ៏ធំធេងសម្រាប់ប្រជាជន និងប្រទេសទាំងពីរ ទាំងក្នុងពេលបច្ចុប្បន្ន និងទៅអនាគត។

ក្នុងឱកាសនោះ ឯកឧត្តមប្រធានាធិបតីបានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះប្រទេសកម្ពុជា ដែលបានគាំទ្រប្រទេសទីម័រឡេស្តេចូលជាសមាជិកអាស៊ាន។ ឯកឧត្តមមានជំនឿជឿជាក់ថា ប្រទេសទាំងពីរនឹងខិតខំពង្រឹងពង្រីកទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការឱ្យកាន់តែរីកធំធាត់បន្ថែមទៀត ជាពិសេសលើវិស័យពាណិជ្ជកម្ម និងសេដ្ឋកិច្ច។ ជាមួយគ្នានេះ ប្រទសកម្ពុជាក៏អាចនាំអង្ករ និងសម្ភារៈផ្សេងៗទៅកាន់ប្រទេសទីម័រឡេស្តេផងដែរ។

ឯកឧត្តប្រធានាធិបតីបានបញ្ជាក់ថា នៅពេលដែលប្រទេសទីម័រឡេស្តេបានចូលជាសមាជិកអាស៊ាន ប្រទេសទីម័រឡេស្តេនឹងខិតខំប្រឹងប្រែងឱ្យអស់ពីកម្លាំងកាយចិត្តថែមទៀត ដើម្បីធ្វើយ៉ាងណាពង្រឹងពង្រីកទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការជាមួយនឹងប្រទេសជាសមាជិកអាស៊ានទាំងអស់ ព្រមទាំងលើកកម្ពស់ការថែរក្សាសន្តិភាព និងស្ថិរភាពនៅក្នុងតំបន់ ប្រកបដោយវិបុលភាព និងចីរភាព។

តាមរយៈជំនួបសវនាការនាពេលនោះ ឯកឧត្តមប្រធានាធិបតីសង្ឃឹមថា នឹងខិតខំប្រឹងប្រែងពង្រឹងពង្រីកនូវទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំពីរឱ្យកាន់តែ





*ទិដ្ឋភាពក្នុងពិធីជំនួបសម្តែងការគួរសម*

រឹងមាំថែមទៀត ជាពិសេសការឈានដល់ការចុះហត្ថលេខាលើកិច្ចព្រមព្រៀងឱ្យមានការហោះហើរ និងការផ្លាស់ប្តូរការធ្វើដំណើរតាមផ្លូវអាកាស។ ជាងនេះទៅទៀតឯកឧត្តមនឹងខិតខំបង្កឱកាសឱ្យសហគ្រិនកម្ពុជាទៅវិនិយោគនៅប្រទេសទីម័រឡេស្តេ។

ឯកឧត្តមប្រធានាធិបតីបានសម្តែងនូវការស្វាគមន៍ចំពោះការលើកកម្ពស់ទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការរវាងអង្គការនីតិប្បញ្ញត្តិនៃប្រទេសទាំងពីរ។ ជាមួយគ្នានោះ ឯកឧត្តមក៏បានគោរពអញ្ជើញសម្តេចប្រធានព្រឹទ្ធសភាទៅបំពេញទស្សនកិច្ចជាផ្លូវការនៅសាធារណរដ្ឋប្រជាធិបតេយ្យទីម័រឡេស្តេក្នុងពេលវេលាសមស្របណាមួយ។

សម្តេចប្រធានព្រឹទ្ធសភាបានសម្តែងនូវសេចក្តីរីករាយ និងវាយតម្លៃខ្ពស់ចំពោះទំនាក់ទំនងកិច្ចសហប្រតិបត្តិការរវាងប្រជាជន និងប្រទេសទាំងពីរ ដែលមានការរីកចម្រើនជាលំដាប់។ ការរីកចម្រើននេះបានស្តែងឡើងតាមរយៈការផ្លាស់ប្តូរដំណើរទស្សនកិច្ចរបស់ថ្នាក់ដឹកនាំគ្រប់ជាន់ថ្នាក់នៃប្រទេសទាំងពីរ ជំនួបតាមប្រព័ន្ធវីដេអូ ការផ្ញើសារជូនពរទៅវិញទៅមក និងការគាំទ្រគ្នាទៅវិញទៅមកក្នុងក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការអន្តរជាតិ។

សម្តេចប្រធានព្រឹទ្ធសភាបានឯកភាពចំពោះប្រសាសន៍របស់ឯកឧត្តមប្រធានាធិបតី ដែលមានបំណងធ្វើការផ្លាស់ប្តូរពាណិជ្ជកម្មរវាងប្រទេសទាំងពីរឱ្យកាន់តែមានទំហំធំថែមទៀត។ សម្តេចប្រធានព្រឹទ្ធសភាបានអបអរសាទរ និងគាំទ្រកិច្ចព្រមព្រៀង និងអនុស្សរណៈយោគយល់គ្នា ដែលមានស្រាប់ គឺកិច្ចព្រមព្រៀង និងអនុស្សរណៈយោគយល់គ្នាដែលបានចុះហត្ថលេខារវាងប្រទេសទាំងពីរ ក្នុងដំណើរទស្សនកិច្ចរបស់ឯកឧត្តមប្រធានាធិបតីនាឱកាសនេះ។ ក្នុងនាមព្រឹទ្ធសភា និងក្នុងនាមសម្តេចផ្ទាល់ សម្តេចប្រធានព្រឹទ្ធសភាសូមលើកទឹកចិត្តដល់រដ្ឋាភិបាល នៃប្រទេសទាំងពីរ ចាត់តាំងអនុវត្តឱ្យមានប្រសិទ្ធភាព ដើម្បីជាគុណប្រយោជន៍ដល់វឌ្ឍនភាព វិបុលភាព សុភមង្គល និងការអភិវឌ្ឍរបស់ប្រជាជន និងប្រទេសទាំងពីរ។

សម្តេចប្រធានព្រឹទ្ធសភាបានបញ្ជាក់ថា សភាកម្ពុជាបានចូលរួមយ៉ាងសកម្មក្នុងវេទិកាអន្តរសភានានាដូចជា៖ IPU, AIPA, APF, APPF, ASCEP និង CLV ជាដើម។ ព្រឹទ្ធសភាកម្ពុជាមានបំណងកសាងទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការជិតស្និទ្ធជាមួយនឹងរដ្ឋសភា នៃសាធារណរដ្ឋប្រជាធិបតេយ្យទីម័រឡេស្តេ ដើម្បីរួមចំណែកដល់ការពង្រឹងពង្រីកទំនាក់ទំនងមិត្តភាព និងកិច្ចសហប្រតិបត្តិការរវាងប្រជាជន និងប្រទេសទាំងពីរឱ្យកាន់តែទូលំទូលាយ ស៊ីជម្រៅ និងរឹងមាំជាងនេះទៀត។

សម្តេចប្រធានព្រឹទ្ធសភាបានសម្តែងនូវការកោតសរសើរ និងអបអរសាទរចំពោះរដ្ឋាភិបាល និងប្រជាជនទីម័រខាងកើតដែលសម្រេចបាននូវវឌ្ឍនភាពសេដ្ឋកិច្ច សង្គម ប្រកបដោយជោគជ័យ និងសូមប្រសិទ្ធពរជូនរដ្ឋាភិបាល និងប្រជាជនទីម័រខាងកើតសម្រេចបាននូវជោគជ័យធំៗ និងថ្មីៗជាងនេះទៀត។

ឆ្លើយតបនឹងការអញ្ជើញរបស់ឯកឧត្តមប្រធានាធិបតី សម្តេចប្រធានព្រឹទ្ធសភានឹងរកពេលវេលាសមស្របណាមួយ ដើម្បីទៅបំពេញទស្សនកិច្ចជាផ្លូវការនៅសាធារណរដ្ឋប្រជាធិបតេយ្យទីម័រឡេស្តេ។ តាមរយៈឯកឧត្តមប្រធានាធិបតី សម្តេចបានផ្តាំផ្ញើការសួរសុខទុក្ខដោយសេចក្តីរាប់អាន និងនឹករលឹក ជូនចំពោះឯកឧត្តមប្រធានសភាជាតិ និងថ្នាក់ដឹកនាំជាន់ខ្ពស់ទាំងអស់ នៃសាធារណរដ្ឋប្រជាធិបតេយ្យទីម័រឡេស្តេ។ សម្តេចបានប្រសិទ្ធពរជូនឯកឧត្តមប្រធានាធិបតី និងគណៈប្រតិភូ សូមមានសុខភាពល្អបរិបូរណ៍ និងទទួលបានជ័យជម្នះក្នុងការស្នាក់នៅ និងបំពេញទស្សនកិច្ចផ្លូវការនៅព្រះរាជាណាចក្រកម្ពុជា៕

(អត្ថបទ៖ នុត សច្ច: រូបភាព៖ គង់ យ៉ារីន)



*សម្តេចប្រធានព្រឹទ្ធសភា ថតរូបអនុស្សាវរីយ៍ជាមួយ ឯកឧត្តម ចូហ្សេ រ៉ាម៉ូស ហរតា*

# សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភាជួបសំណេះសំណាលជាមួយនឹង ប្រជាពលរដ្ឋ និងចូលរួមពិធីផ្សេងៗ

❈នារសៀលថ្ងៃព្រហស្បតិ៍ ទី២៩ ខែកញ្ញា ឆ្នាំ២០២២ នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ សម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញទទួលព្រះរាជដំណើរព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ **នរោត្ដម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និងសម្ដេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ស្ដេចយាងនិវត្តន៍ពីទីក្រុងប៉េកាំង នៃសាធារណរដ្ឋប្រជាមានិតចិន។



❈នារសៀលថ្ងៃសុក្រ ទី៣០ ខែកញ្ញា ឆ្នាំ២០២២ សម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញគោរពវិញ្ញាណក្ខន្ធសពព្រឹទ្ធមហាឧបាសិកាពុទ្ធសាសនូបត្ថម្ភក៍ **ទន់ ធី** ត្រូវជាម្ដាយក្មេក ឯកឧត្ដមឧបនាយករដ្ឋមន្ត្រី **យឹម ឆៃលី** ប្រធានក្រុមប្រឹក្សាស្ដារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ និងជាប្រធានគណៈកម្មាធិការជាតិជំរុញចលនាភូមិមួយផលិតផលមួយ នៅគេហដ្ឋានស្ថិតក្នុងភូមិពន្លៃ ឃុំកក់ ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ។




❈នៅថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២២ សម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវ បានអញ្ជើញចូលរួមក្នុងព្រះរាជពិធីឧទ្ទិសព្រះមហាកុសលគម្រប់ខួប១០ព្រះវស្សា ថ្វាយដួងព្រះវិញ្ញាណក្ខន្ធព្រះករុណាព្រះបរមរតនកោដ្ឋ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ **នរោត្ដម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និងសម្ដេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ នៅព្រះបរមរាជវាំង។



## សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភាជួបសំណេះសំណាលជាមួយនឹងប្រជាពលរដ្ឋ និងចូលរួមពិធីផ្សេងៗ

❈នាព្រលប់ថ្ងៃទី២០ ខែតុលា ឆ្នាំ២០២២ សម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញចូលរួមព្រះរាជពិធីលៀងសាយភោជន៍ជូនប្រធានាធិបតី នៃសាធារណរដ្ឋប្រជាធិបតេយ្យទីម័រឡេស្ដេ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា នៅព្រះបរមរាជវាំង។



❈នាព្រឹកថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២២ នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ សម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រធានព្រឹទ្ធសភាបានអញ្ជើញដឹកនាំគណៈប្រតិភូជាន់ខ្ពស់ព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ទៅបំពេញទស្សនកិច្ចផ្លូវការរយៈពេល៣ថ្ងៃ នៅសាធារណរដ្ឋសង្គមនិយមវៀតណាម។



❈នាល្ងាចថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២២ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ស៊ឹម កា** អនុប្រធានទី១ព្រឹទ្ធសភា និងលោកជំទាវ បានអញ្ជើញចូលរួមក្នុងពិធីសូត្រមន្តបុណ្យកឋិនទានសាមគ្គី នៅសាលាខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ដើម្បីដង្ហែទៅវេរប្រគេនព្រះសង្ឃដែលគង់ចាំព្រះវស្សាអស់កាលត្រីមាស នៅបណ្ដាវត្តចំនួន៥ គឺ៖ វត្តទួលសន្និវ័ន្ត (ហៅវត្តទួលអស់លោក) វត្តទួលសុវណ្ណារាម វត្តញាណរង្សី វត្តកោះមេតាពោធិ៍វង្ស និងវត្តឧត្តរាវត្តី ដែលស្ថិតក្នុងខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។



# សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភាជួបសំណេះសំណាលជាមួយនឹងប្រជាពលរដ្ឋ និងចូលរួមពិធីផ្សេងៗ

❈នាព្រឹកថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២២ គណៈប្រតិភូព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ដឹកនាំដោយឯកឧត្តមកិត្តិសង្គហបណ្ឌិត **ទេព ងន** អនុប្រធានទី២ព្រឹទ្ធសភា បានអញ្ជើញគោរពវិញ្ញាណក្ខន្ធសពព្រឹទ្ធមហាឧបាសិកាពុទ្ធសាសនូបត្ថម្ភក៍ **ទន់ ធី** ត្រូវជាម្តាយក្មេករបស់ឯកឧត្តម **យឹម ឆៃលី** ឧបនាយករដ្ឋមន្ត្រី ប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ នៅគេហដ្ឋានស្ថិតក្នុងភូមិពន្លៃ ឃុំកក់ ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ។




❈នាព្រឹកថ្ងៃ១៥ ខែតុលា ឆ្នាំ២០២២ គណៈប្រតិភូព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ដឹកនាំដោយឯកឧត្តមកិត្តិសង្គហបណ្ឌិត **ទេព ងន** អនុប្រធានទី២ព្រឹទ្ធសភា បានអញ្ជើញថ្វាយកម្រងផ្កា និងគោរពព្រះវិញ្ញាណក្ខន្ធព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ "ព្រះបរមរតនកោដ្ឋ" នៅមណ្ឌបតម្កល់ព្រះបរមរូប ជិតវិមានឯករាជ្យ រាជធានីភ្នំពេញ។



❈នាព្រឹកថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២២ ឯកឧត្តមកិត្តិសង្គហបណ្ឌិត **ទេព ងន** អនុប្រធានទី២ព្រឹទ្ធសភាបានអញ្ជើញធ្វើបទឧទ្ទេសនាមស្តីពី ភាពជាអ្នកដឹកនាំជូនដល់សិក្ខាកាមជាអភិបាលរងរាជធានី ខេត្តទាំង២៥ ដែលទើបទទួលបានការតែងតាំងថ្មី នៅទីស្តីការក្រសួងមហាផ្ទៃ៕



# គណៈកម្មការទី១ព្រឹទ្ធសភា ក្រសួងមហាផ្ទៃ និងក្រសួងពាក់ព័ន្ធ ប្រជុំពិភាក្សាលើសំណើរបស់ជនជាតិដើមភាគតិច



*គណៈកម្មការទី១ព្រឹទ្ធសភាប្រជុំពិភាក្សាលើជាមួយក្រសួងពាក់ព័ន្ធ*

នាព្រឹកថ្ងៃទី៥ ខែតុលា ឆ្នាំ២០២២ គណៈកម្មការសិទ្ធិមនុស្ស ទទួលពាក្យបណ្ដឹង និងអង្កេត នៃព្រឹទ្ធសភា (គណៈកម្មការទី១) ដឹកនាំដោយឯកឧត្តម **យ៉ង់ សែម** ប្រធានគណៈកម្មការ បានប្រជុំពិភាក្សាការងារជាមួយនឹងលេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប.) តំណាងមកពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តំណាងក្រសួងបរិស្ថាន និងតំណាងក្រសួងមហាផ្ទៃ ដែលដឹកនាំដោយឯកឧត្តម **ចាន់ សុធា** អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានលេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប.) នៅសាលសិក្ខាសាលាបណ្ណាល័យព្រឹទ្ធសភា។

ក្នុងឱកាសនោះ ឯកឧត្តម **យ៉ង់ សែម** បានជម្រាបជូនអង្គប្រជុំអំពីគោលបំណង នៃជំនួបពិភាក្សាគឺ ដើម្បីឈ្វេងយល់ និងប្រមូលព័ត៌មានឱ្យបានគ្រប់ជ្រុងជ្រោយក្នុងការធ្វើរបាយការណ៍គោរពរាយការណ៍ជូនថ្នាក់ដឹកនាំព្រឹទ្ធសភាទាក់ទងនឹងសំណើរបស់តំណាងជនជាតិដើមភាគតិចចំនួន ១៦នាក់ មកពី១៦អម្បូរជនជាតិ និងតំណាងឱ្យសហគមន៍ជនជាតិដើម១២ខេត្ត ក្រុង ដែលបានដាក់សំណើគោរពជូន



*ក្រសួងមហាផ្ទៃ និងក្រសួងពាក់ព័ន្ធចូលរួមក្នុងកិច្ចប្រជុំពិភាក្សាលើសំណើរបស់ជនជាតិដើមភាគតិច*




*ទិដ្ឋភាពក្នុងកិច្ចប្រជុំពិភាក្សាការងារ*

សម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា ដើម្បីសុំការអនុញ្ញាតជួប និងគោរពផ្ដល់ជូននូវសេចក្ដីថ្លែងការណ៍រួម និងរបាយការណ៍ នៃលទ្ធផលពិគ្រោះយោបល់ ផ្ដល់ធាតុចូលលើសេចក្ដីព្រាងវិសោធនកម្មច្បាប់ស្ដីពី តំបន់ការពារធម្មជាតិឆ្នាំ២០០៨ និងច្បាប់ស្ដីពី ព្រៃឈើឆ្នាំ២០០២។

បន្ទាប់ពីឯកឧត្ដម **ចាន់ សុធា** អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានលេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ បានធ្វើសេចក្ដីរាយការណ៍ជូនអង្គប្រជុំជ្រាបអំពីការរៀបចំវិសោធនកម្មច្បាប់ស្ដីពី ព្រៃឈើ ប្រកាសឱ្យប្រើនៅឆ្នាំ២០០២ ច្បាប់ស្ដីពី ជលផល ប្រកាសឱ្យប្រើនៅឆ្នាំ២០០៦ និងច្បាប់ស្ដីពី តំបន់ការពារ ដែលបានប្រកាសឱ្យប្រើនៅឆ្នាំ២០០៨ រួចមក ឯកឧត្ដម **យ៉ង់ សែម** បានវាយតម្លៃខ្ពស់ និងកោតសរសើរទៅដល់រាជរដ្ឋាភិបាល ជាពិសេសក្រសួងមហាផ្ទៃ ក្រសួងបរិស្ថាន និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលបានយកសំណូមពរ និងសំណើរបស់តំណាងជនជាតិដើមភាគតិចចំនួន១៦នាក់ មកដោះស្រាយដោយស្មោះអស់ពីចិត្ត។ តាមរយៈការខិតខំរបស់រាជរដ្ឋាភិបាល ពិតជាបានបង្ហាញនូវការយកចិត្តទុកដាក់ក្នុងការដោះស្រាយរួមនូវសំណូមពររបស់ប្រជាពលរដ្ឋសហគមន៍៕

(អត្ថបទ៖ វង់ សុជាតិ រូបភាព៖ ធុន គីមជី)



*ទិដ្ឋភាពក្នុងកិច្ចប្រជុំពិភាក្សាការងារ*

# គណៈកម្មការទី១ព្រឹទ្ធសភា និងក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨ជួបពិភាក្សាការងារជាមួយតំណាងជនជាតិដើមភាគតិច




*គណៈកម្មការទី១ព្រឹទ្ធសភា និងក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨ ជួបជាមួយតំណាងជនជាតិតិច*

នាព្រឹកថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២២ នៅសាលប្រជុំពិសេស៣ វិមានព្រឹទ្ធសភា គណៈកម្មការសិទ្ធិមនុស្ស ទទួលពាក្យបណ្តឹង និងអង្កេត នៃព្រឹទ្ធសភា (គណៈកម្មការទី១) និងក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨ ដឹកនាំដោយ ឯកឧត្តម **យ៉ន់ សែម** ប្រធានគណៈកម្មការ និងជាប្រធានក្រុម បានទទួលជួបពិភាក្សាការងារជាមួយនឹងតំណាងជនជាតិដើមភាគតិចចំនួន១៦នាក់ មកពី១៦អម្បូរជនជាតិ និងតំណាងឱ្យសហគមន៍ជនជាតិដើម១២ខេត្ត ក្រុង។

នៅក្នុងឱកាសនោះ កញ្ញា **ភ្លាន សារិត** តំណាងឱ្យជនជាតិដើមភាគតិចចារ៉ាយ បានជម្រាបជូនអង្គប្រជុំអំពីសំណើរបស់ជនជាតិភាគតិច ស្នើសុំដាក់បញ្ចូលធាតុចូលទៅក្នុងសេចក្តីព្រាងច្បាប់វិសោធនកម្មច្បាប់ស្តីពី តំបន់ការពារធម្មជាតិ និងច្បាប់ស្តីពី ព្រៃឈើ ចំនួន៨ចំណុច រួមមាន៖ **១**-ការបញ្ញត្តិសហគមន៍ជនជាតិដើមភាគតិចខុសគ្នាពីសហគមន៍មូលដ្ឋាន **២**-ចម្ការពនេចរ ឬចម្ការវិលជុំ **៣**-អភិបាលកិច្ច សិទ្ធិធម្មានុរូប **៤**-ស្នើសេចក្តីព្រាងវិសោធនកម្មច្បាប់ទាំងពីរគួរមានជំពូកមួយដោយឡែក **៥**-ស្នើរយៈពេលកិច្ចព្រមព្រៀងសហគមន៍ព្រៃឈើ និងសហគមន៍តំបន់ធម្មជាតិគួរមានរយៈពេលដូចកិច្ចសន្យាដីសម្បទានសេដ្ឋកិច្ច ហើយមិនគួរផ្អាក ឬលុបចោលកិច្ចព្រមព្រៀងសហគមន៍ឡើយ **៦**-ស្នើសេចក្តីព្រាងវិសោធនកម្មច្បាប់ទាំងពីរនេះ គួរដាក់បញ្ញត្តិឱ្យរដ្ឋផ្តល់ធនធានថវិកាជាតិ **៧**-ស្នើសេចក្តីព្រាងវិសោធនកម្មច្បាប់ទាំងពីរនេះ គួរដាក់បញ្ញត្តិកាតព្វកិច្ចឱ្យរដ្ឋអនុវត្តគោលការណ៍ នៃការស្នើសុំការឯកភាពជាមុន ដោយសេរីបន្ទាប់ពីទទួលបានព័ត៌មានត្រឹមត្រូវគ្រប់ជ្រុងជ្រោយ និងពេលវេលាគ្រប់គ្រាន់ និង **៨**-ស្នើសេចក្តីព្រាងវិសោធនកម្មច្បាប់ទាំងពីរនេះ គួរមានមាត្រាជាក់លាក់បញ្ញត្តិអំពី ការកំណត់ទំហំ ទីតាំង ព្រំដីព្រៃ




*តំណាងជនជាតិដើមភាគតិច ជួបពិភាក្សាជាមួយគណៈកម្មការទី១ព្រឹទ្ធសភា និងក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨*



*ទិដ្ឋភាពក្នុងពិធីជួបពិភាក្សាការងារ*

ភ្នំ បឹង ជំនឿ ប្រាសាទ ទីតាំងវប្បធម៌ ឈរលើការចង្អុលបង្ហាញតាមស្ថានភាពជាក់ស្ដែង ដោយជនជាតិដើមភាគតិច និងសហគមន៍ជិតខាង ហើយមានអាជ្ញាធរចូលរួមដឹងឮ។

មានប្រសាសន៍នៅក្នុងជំនួបនោះ ឯកឧត្ដម **យ៉ង់ សែម** បានពាំនាំនូវការផ្ដាំផ្ញើសួរសុខទុក្ខពីថ្នាក់ដឹកនាំព្រឹទ្ធសភាជូនចំពោះបងប្អូនជនជាតិដើមភាគតិចទាំងអស់។ ឯកឧត្ដមបានជម្រាបជូនតំណាជនជាតិដើមភាគតិចអំពីលទ្ធផល នៃជំនួបពិភាក្សារវាងគណៈកម្មការទី១ព្រឹទ្ធសភា ជាមួយនឹងថ្នាក់ដឹកនាំលេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបលទ្ធិប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប.) នៃក្រសួងមហាផ្ទៃ និងក្រសួងពាក់ព័ន្ធ កាលពីពេលកន្លងទៅ ដោយបានទទួលនូវព័ត៌មានយ៉ាងច្បាស់លាស់អំពីការដាក់បញ្ចូលធាតុចូលទាំង៨ចំណុច គឺសឹងតែគ្រប់ចំណុចទាំងអស់ ត្រូវបានដាក់បញ្ចូលទៅក្នុងមាត្រានានានៅក្នុងសេចក្ដីព្រាងច្បាប់ស្ដីពី តំបន់ការពារធម្មជាតិ និងសេចក្ដីព្រាងច្បាប់ស្ដីពីព្រៃឈើ នៅសល់តែ៣ចំណុចប៉ុណ្ណោះ ដែលក្រសួងកំពុងពិនិត្យ និងសម្រេច។

ជំនួបពិភាក្សានោះ រៀបចំដើម្បីឈ្វេងយល់ទាក់ទងនឹងសំណើរបស់តំណាងជនជាតិដើមភាគតិច ដែលបានដាក់សំណើគោរពជូនសម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា ដើម្បីសុំការអនុញ្ញាតជួប និងគោរពផ្ដល់ជូននូវសេចក្ដីថ្លែងការណ៍រួម និងរបាយការណ៍ នៃលទ្ធផលពិគ្រោះយោបល់ផ្ដល់ធាតុចូលលើសេចក្ដីព្រាងវិសោធនកម្មច្បាប់ស្ដីពីតំបន់ការពារធម្មជាតិឆ្នាំ២០០៨ និងច្បាប់ស្ដីពី ព្រៃឈើឆ្នាំ២០០២។

បន្ទាប់ពីជំនួបពិភាក្សារួចមក ប្រតិភូតំណាងជនជាតិដើមភាគតិច ក៏បានអញ្ជើញទស្សនាអគារនានាដែលជាទីតាំងប្រវត្តិសាស្ត្រនៅក្នុងបរិវេណវិមានព្រឹទ្ធសភាផងដែរ៕

(អត្ថបទ៖ ធុន គីមជី រូបភាព៖ គង់ យ៉ារីន)



*គណៈកម្មការទី១ព្រឹទ្ធសភា និងក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨ ថតរូបអនុស្សាវរីយ៍ជាមួយតំណាងជនជាតិដើមភាគតិច*

# ព្រះសង្ឃ សាស្ត្រាចារ្យ និងនិស្សិត នៃសាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច ខេត្តបាត់ដំបង ទស្សនកិច្ចសិក្សាឈ្វេងយល់អំពីព្រឹទ្ធសភា



*ឯកឧត្តម យ៉េង សែម អញ្ជើញធ្វើបទបង្ហាញ*

នារសៀលថ្ងៃទី៥ ខែតុលា ឆ្នាំ២០២២ ព្រះសង្ឃ សាស្ត្រាចារ្យ និងនិស្សិត នៃសាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច ខេត្តបាត់ដំបង ចំនួន២៥នាក់ បាននិមន្ត និងអញ្ជើញមកទស្សនកិច្ចសិក្សាឈ្វេងយល់អំពី ការរៀបចំ និងដំណើរការប្រព្រឹត្តទៅរបស់ព្រឹទ្ធសភា នៅវិមានព្រឹទ្ធសភា។

ក្នុងឱកាសនៃដំណើរទស្សនកិច្ចនោះ ឯកឧត្តម **យ៉េង សែម** ប្រធានគណៈកម្មការទី១ព្រឹទ្ធសភា បានអញ្ជើញទទួលស្វាគមន៍ និងធ្វើបទបង្ហាញស្ដីពី រចនាសម្ព័ន្ធ តួនាទី និងភារកិច្ចរបស់ព្រឹទ្ធសភា និងតួនាទី ភារកិច្ច សមត្ថកិច្ចរបស់គណៈកម្មការសិទ្ធិមនុស្ស ទទួលពាក្យបណ្ដឹង និងអង្កេត នៃព្រឹទ្ធសភា ប្រគេន និងជម្រាបជូនអង្គពិធីជ្រាបអំពីប្រវត្តិ និងគោលបំណង នៃការបង្កើតព្រឹទ្ធសភា។ ព្រឹទ្ធសភានីតិកាលទី១ កើតឡើងដោយសារការតែងតាំង។ ចាប់ពីនីតិកាលទី២ ព្រឹទ្ធសភាកើតឡើងពីការបោះឆ្នោតជាអសកលមិនចំពោះ។ ព្រឹទ្ធសភាមានចំនួនសមាជិកយ៉ាងច្រើនស្មើនឹងពាក់កណ្ដាល នៃចំនួនសមាជិករដ្ឋសភាទាំងមូល។ សមាជិកព្រឹទ្ធសភា ត្រូវបានចាត់តាំងខ្លះ និងត្រូវជ្រើសតាំងដោយការបោះឆ្នោតអសកលខ្លះ មានអាណត្តិ៦ឆ្នាំ។ អង្គបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា គឺតំណាងរាស្ត្រ និងក្រុមប្រឹក្សាឃុំ សង្កាត់ទូទាំងប្រទេសក្នុងតំណែង។

ឯកឧត្តមបានបញ្ជាក់ថា ព្រឹទ្ធសភាជាអង្គការដែលមានអំណាចនីតិប្បញ្ញត្តិ ហើយបំពេញភារកិច្ចរបស់ខ្លួន ដូចមានចែងក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់ជាធរមាន។ ព្រឹទ្ធសភាមានមុខងារស្នូលចំនួន៣គឺ៖ មុខងារនីតិកម្ម មុខងារតាមដានការអនុវត្តច្បាប់ និងមុខងារតំណាង។ ក្រៅពីនេះ ព្រឹទ្ធសភាមានមុខងារគាំទ្រចំនួន២ទៀត គឺមុខងារសហប្រតិបត្តិការអន្តរជាតិ និងមុខងារអភិវឌ្ឍន៍ស្ថាប័ន។ ជាមួយគ្នានេះ ព្រឹទ្ធសភាមានគណៈកម្មការជំនាញចំនួន១០ ក្នុងនោះគណៈកម្មការសិទ្ធិមនុស្ស ទទួលពាក្យបណ្ដឹង និងអង្កេត នៃព្រឹទ្ធសភា មានតួនាទីជាសេនាធិការឱ្យព្រឹទ្ធសភាក្នុងការបំពេញ



*ទិដ្ឋភាពក្នុងពិធីធ្វើបទបង្ហាញ*





*ទិដ្ឋភាពក្នុងពិធីធ្វើបទបង្ហាញ*

មុខងារនីតិកម្ម មុខងារតាមដានការអនុវត្តច្បាប់ និងមុខងារផ្តល់ព័ត៌មាន ព្រមទាំងធានាការស្វែងរកព័ត៌មានពាក់ព័ន្ធនឹងវិស័យខ្លួន។ គណៈកម្មការមានភារកិច្ចគាំទ្រលើកស្ទួយ និងការពារសិទ្ធិជនគ្រប់រូបឱ្យមានសេចក្តីថ្លៃថ្នូរ និងមានសិទ្ធិស្មើគ្នា តាមដានត្រួតពិនិត្យនូវការអនុវត្តសិទ្ធិមនុស្សនៅកម្ពុជា ឱ្យបានសមស្របទៅតាមលិខិតបទដ្ឋានគតិយុត្តនានា។

នៅក្នុងឱកាសនោះដែរ លោក **សុខ សុជាតិ** ជំនួយការអគ្គលេខាធិការព្រឹទ្ធសភា ក៏បានធ្វើបទបង្ហាញស្តីពី ដំណើរការនីតិកម្មរបស់ព្រឹទ្ធសភា និងលោកស្រី **ឃុន សុវណ្ណនេត្រា** ប្រធាននាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស ធ្វើបទបង្ហាញស្តីពី រចនាសម្ព័ន្ធ តួនាទី និងភារកិច្ច របស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាផងដែរ។

បន្ទាប់ពីស្តាប់បទបង្ហាញរួចមក ព្រះសង្ឃ សាស្ត្រាចារ្យ និស្សិត បាននិមន្ត និងអញ្ជើញទស្សនាសាលប្រជុំព្រឹទ្ធសភា បណ្ណាល័យព្រឹទ្ធសភា និងអគារប្រវត្តិសាស្ត្រនានានៅក្នុងបរិវេណព្រឹទ្ធសភា៕

(អត្ថបទ៖ គឹម សិទ្ធី រូបភាព៖ គង់ យ៉ារីន)



*ឯកឧត្តម យ៉ង់ សែម ប្រគល់វត្ថុអនុស្សាវរីយ៍ជូនតំណាងសាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច ខេត្តបាត់ដំបង*



*ឯកឧត្តម យ៉ង់ សែម ថតរូបអនុស្សាវរីយ៍ជាមួយព្រះសង្ឃ សាស្ត្រាចារ្យ និងនិស្សិត នៃសាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច ខេត្តបាត់ដំបង*

# សភាកម្ពុជារៀបចំសិក្ខាសាលាចំនួន៣ថ្ងៃស្ដីពីស្វ័យភាពសេដ្ឋកិច្ចរបស់ស្ត្រី នៅតំបន់ជនបទ និងវិធីសាស្ត្រ នៃការចរចាប្រើប្រាស់នៅក្នុងក្របខ័ណ្ឌកិច្ចការសភា




*លោកជំទាវ ទី បូរ៉ាស៊ី (កណ្ដាល) អញ្ជើញជាអធិបតីភាពក្នុងអង្គសិក្ខាសាលា*

នាថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២២ ព្រឹទ្ធសភា រដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជាបានបើកសិក្ខាសាលាក្នុងក្របខ័ណ្ឌសភាប្រើភាសាបារាំង ស្ដីពីស្វ័យភាពសេដ្ឋកិច្ចរបស់ស្ត្រីនៅតំបន់ជនបទ និងវិធីសាស្ត្រ នៃការចរចាប្រើប្រាស់នៅក្នុងក្របខ័ណ្ឌកិច្ចការសភា ក្រោមអធិបតីភាពលោកជំទាវ **ទី បូរ៉ាស៊ី** ប្រធានគណៈកម្មការទី៥ព្រឹទ្ធសភា អនុប្រធាននៃក្រុមសភាជាតិកម្ពុជា-APF និងជាប្រធានបណ្ដាញស្ត្រីនៃសភាជាតិកម្ពុជា-APF នៅវិមានព្រឹទ្ធសភា។

សិក្ខាសាលានេះ មានការអញ្ជើញចូលរួមផ្ទាល់ពីសមាជិក សមាជិកាព្រឹទ្ធសភា រដ្ឋសភា ភ្ញៀវជាតិ និងអន្តរជាតិចំនួន១៣០នាក់ ព្រមទាំងមានការចូលរួមតាមរយៈប្រព័ន្ធវីដេអូពីសមាជិកសភា នៃបណ្ដាប្រទេសក្នុងតំបន់អាស៊ី-ប៉ា-ស៊ីហ្វិក និងអ្នកជំនាញវាយតម្លៃការអនុវត្ត SDGs របស់អង្គការ APEA, UNFPA, EvalYouth (Global Network) និង EvalYouth (Asia Chapter) សរុបប្រមាណជាង២០០នាក់។

ក្នុងឱកាសបើកសិក្ខាសាលានោះ ក្នុងនាមក្រុមសភាជាតិកម្ពុជា នៃសភានិយាយភាសាបារាំង និងក្នុងនាមអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងរដ្ឋសភា ឯកឧត្តម **ឡេង ប៉េងឡុង** អគ្គលេខាធិការរដ្ឋសភា បានបញ្ជាក់ថា ការរៀបចំសិក្ខាសាលានាពេលនេះ បានឆ្លុះបញ្ចាំងឱ្យឃើញពីភាពសកម្ម និងឆន្ទៈ នៃសហប្រតិបត្តិការដ៏ល្អប្រពៃរបស់សភាប្រើភាសាបារាំង ដើម្បីចែករំលែកនូវចំណេះដឹង និងការអនុវត្តល្អៗទោះបីជាពិភពលោកស្ថិតក្នុងបរិបទ នៃភាពមិនទៀងទាត់។ ជាមួយគ្នានោះ ឯកឧត្តមក៏បានសម្ដែងនូវការស្វាគមន៍យ៉ាងកក់ក្ដៅចំពោះភ្ញៀវជាតិ អន្តរជាតិទាំងអស់





*ទិដ្ឋភាពក្នុងអង្គសិក្ខាសាលា*

ដែលនឹងរួមចំណែកផ្តល់ធាតុចូលសំខាន់ៗដល់អង្គសិក្ខាសាលា តាមរយៈការចែករំលែកនូវទស្សនៈ គំនិត បទពិសោធន៍ និងអនុសាសន៍ល្អៗ ជាគុណប្រយោជន៍ដល់ការសិក្សាពិចារណា សម្រាប់យកទៅអនុវត្តឱ្យបានសមស្របទៅនឹងលក្ខខណ្ឌនយោបាយ សេដ្ឋកិច្ច សង្គម និងវប្បធម៌ ដោយឡែករបស់កម្ពុជានាយុគសម័យបច្ចុប្បន្ន។

បន្ទាប់ពីការឡើងថ្លែងមតិស្វាគមន៍របស់ឯកឧត្តមអគ្គលេខាធិការរដ្ឋសភារួចមក លោកជំទាវ Latifa Gahouchi សមាជិកា នៃសភាសហព័ន្ធវ៉ាល់ឡូនី-ព្រុចសែលប៊ែលហ្ស៊ិក បានឡើងថ្លែងសុន្ទរកថារបស់លោកជំទាវ Maryse Gaudreault ប្រធានបណ្តាញស្ត្រីសភាប្រើប្រាស់ភាសាបារាំង ដោយបញ្ជាក់ថា ការរៀបចំសិក្ខាសាលានាពេលនេះ ដើម្បីពិភាក្សាអំពីការយកចិត្តទុកដាក់ជាពិសេស ស្តីពីស្ថានភាពរបស់ស្ត្រីនៅតំបន់ជនបទនៅកម្ពុជា ជាមួយនឹងបទពិសោធន៍របស់ប្រទេសជិតខាង និងសហគមន៍អឺរ៉ុប ព្រមទាំងផ្តល់ព័ត៌មានជូនសមាជិកសភាអំពីឧបសគ្គនានា ដែលស្ត្រីនៅតំបន់ជនបទបានជួបប្រទះ ដើម្បីស្វែងរកយុទ្ធសាស្ត្រលើកកម្ពស់ស្វ័យភាពសេដ្ឋកិច្ចរបស់ស្ត្រីទាំងនោះ។

មានប្រសាសន៍បើកសិក្ខាសាលានាពេលនោះ ក្នុងនាមសភាកម្ពុជា លោកជំទាវ **ទី ម៉ូវ៉ាស៊ី** ប្រធានគណៈកម្មការទី៥ព្រឹទ្ធសភា អនុប្រធាន នៃក្រុមសភាជាតិកម្ពុជា-APF និងជាប្រធានបណ្តាញស្ត្រី នៃសភាជាតិកម្ពុជា-APF បានបញ្ជាក់ថា សភាកម្ពុជា ក៏ដូចជាបណ្តាសភាជាច្រើននៅក្នុងពិភពលោក បានយកចិត្តទុកដាក់យ៉ាងខ្លាំងអំពីសារៈសំខាន់ នៃសមភាពពេញលេញរវាងស្ត្រី និងបុរស។ សិក្ខាសាលានៅថ្ងៃនេះ គឺផ្តោតសំខាន់ទៅលើ៖ ១-បញ្ហាសមភាពរវាងស្ត្រី និងបុរស បានចារឹកនៅក្នុងអនុសញ្ញាឆ្នាំ១៩៧៩ ស្តីពីការលុបបំបាត់រាល់ទម្រង់ នៃការរើសអើងចំពោះស្ត្រី ដែលអនុម័តយល់ព្រមដោយប្រទេសហត្ថលេខី ក្នុងនោះក៏មានប្រទេសកម្ពុជាជាសមាជិកផងដែរ។ **២**-ចំពោះប្រធានបទទី២ជាប្រធានបទពាក់ព័ន្ធនឹងវិស័យការទូតអំពីរបៀបទទួលយកនូវការខ្វែងគំនិតគ្នា និងជំរុញការប្រជុំឱ្យមានកិច្ចដំណើរការទៅមុខលើចំណុចផ្សេងៗ ដែលជាផលប្រយោជន៍រួម ឬករណីបន្ទាន់។

លោកជំទាវកិត្តិនីតិកោសលបណ្ឌិតសង្ឃឹមថា ប្រធានបទទាំងពីរដែលលើកយកមកពិភាក្សានាពេលខាងមុខនេះ គឺជាកិច្ចការស្នូល នៃការងារសភា និងជាគុណតម្លៃដែលត្រូវបានការពារដោយសភាប្រើភាសាបារាំង ដើម្បីលទ្ធិប្រជាធិបតេយ្យ និងនីតិរដ្ឋ។ អាស្រ័យហេតុនេះ សូមលោកជំទាវ ឯកឧត្តម និងប្អូនៗជាមន្ត្រីយកចិត្តទុកដាក់ចូលរួមឱ្យបានសកម្មក្នុងវគ្គសំណួរ ចម្លើយ ដើម្បីចងចាំគោលសំខាន់ៗ សម្រាប់យកមកប្រើប្រាស់បម្រើស្ថាប័ន។

សិក្ខាសាលានេះរៀបចំដោយព្រឹទ្ធសភា រដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា សហការជាមួយនឹងសភាប្រើភាសាបារាំង និងមជ្ឈមណ្ឌលសភាអាស៊ី ប្រព្រឹត្តទៅរយៈពេលបីថ្ងៃ ចាប់ថ្ងៃទី២៧ ដល់ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២២ ដោយមានការពិភាក្សាផ្តោតសំខាន់ទៅលើប្រធានបទចំនួន ២គឺ៖ ទី១.ស្វ័យភាពសេដ្ឋកិច្ចរបស់ស្ត្រីនៅតំបន់ជនបទ។ ទី២.វិធីសាស្ត្រនៃការចរចាប្រើប្រាស់នៅក្នុងក្របខ័ណ្ឌកិច្ចការសភា៕

(អត្ថបទ៖ វង់ សុជាតិ រូបភាព៖ អ៊ុក ប៉ូលីន)



*អ្នកចូលរួមសិក្ខាសាលាថតរូបអនុស្សាវរីយ៍នៅខាងមុខអគារក្រហម នៃវិមានព្រឹទ្ធសភា*

# គណៈកម្មការទី១០ព្រឹទ្ធសភាអញ្ជើញជួបពិភាក្សាការងារ ជាមួយគណៈប្រតិភូព្រឹទ្ធសភាថៃ



*គណៈកម្មការទី១០ព្រឹទ្ធសភាជួបពិភាក្សាការងារជាមួយគណៈប្រតិភូព្រឹទ្ធសភាថៃ*

នាព្រឹកថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២២ គណៈកម្មការអង្កេត បោសសម្អាត និងប្រឆាំងអំពើពុករលួយ នៃព្រឹទ្ធសភា (គណៈកម្មការទី១០) ដឹកនាំដោយឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការ បានអញ្ជើញជួបពិភាក្សា និងផ្លាស់ប្តូរបទពិសោធន៍ការងារជាមួយនឹងគណៈប្រតិភូ គណៈកម្មការស៊ើបអង្កេត អំពើពុករលួយ ការប្រព្រឹត្តខុស និងពង្រឹងអភិបាលកិច្ចល្អរបស់ព្រឹទ្ធសភា នៃព្រះរាជាណាចក្រថៃឡង់ដ៍ ដឹកនាំដោយឯកឧត្តមឧត្តមនាវីឯក **សិសថាវ័ត ខន្យ សុវណ្ណ** ប្រធានគណៈកម្មការ នៅសាលសិក្ខាសាលាខាងជើង វិមានព្រឹទ្ធសភា។

ជំនួបពិភាក្សានោះ ក៏មានការអញ្ជើញចូលរួមពីឯកឧត្តម កិត្តិនីតិកោសលបណ្ឌិត **ឱម យិនទៀង** ទេសរដ្ឋមន្ត្រី និងជាប្រធានអង្គភាពប្រឆាំងអំពើពុករលួយ និងសមាជិក សមាជិកាក្រុមមិត្តភាពទ្វេភាគីព្រឹទ្ធសភាកម្ពុជាជាមួយនឹងសភា នៃព្រះរាជាណាចក្រថៃឡង់ដ៍ ព្រមទាំងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។

ក្នុងនាមគណៈកម្មការទី១០ព្រឹទ្ធសភា និងក្រុមមិត្តភាពទ្វេភាគីព្រឹទ្ធសភាកម្ពុជាជាមួយនឹងសភាព្រះរាជាណាចក្រថៃឡង់ដ៍ និងក្នុងនាមឯកឧត្តមផ្ទាល់ ឯកឧត្តម **ម៉ម ប៊ុននាង** បានសម្តែងនូវការស្វាគមន៍គណៈប្រតិភូ ដែលបានអញ្ជើញជួបពិភាក្សាការងារជាមួយគ្នា។

ឯកឧត្តមបានជម្រាបជូនគណៈប្រតិភូអំពីសាវតារ និងការរៀបចំ និងការប្រព្រឹត្តទៅរបស់ព្រឹទ្ធសភាកម្ពុជា ដែលមានមុខងារស្នូលចំនួនបីគឺ៖ មុនងារនីតិកម្ម មុខងារតាម-



*គណៈប្រតិភូព្រឹទ្ធសភាថៃជួបពិភាក្សាការងារជាមួយគណៈកម្មការទី១០ព្រឹទ្ធសភា*



*ទិដ្ឋភាពក្នុងពិធីជំនួបពិភាក្សាការងារ*

ដានការអនុវត្តច្បាប់ និងមុខងារតំណាង។ ក្រៅពីនេះ ព្រឹទ្ធសភានៅមានមុខងារគាំទ្រចំនួន២ទៀតគឺ៖ មុខងារកិច្ចសហប្រតិបត្តិការអន្តរជាតិ និងមុខងារអភិវឌ្ឍស្ថាប័ន។ ជាមួយគ្នានោះ ឯកឧត្តម **ម៉ម ប៊ុននាង** ក៏បានបញ្ជាក់អំពីតួនាទីស្នូល និងការទទួលខុសត្រូវរបស់គណៈកម្មការអង្កេត បោសសម្អាត និងប្រឆាំងអំពើពុករលួយ នៃព្រឹទ្ធសភាកម្ពុជាផងដែរ។

ក្នុងឱកាសនោះ ឯកឧត្តមឧត្តមនារីឯក **សិសថាវ៉ាត វង្ស សុវណ្ណ** បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ឯកឧត្តម **ម៉ម ប៊ុននាង** ដែលបានជម្រាបជូនគណៈប្រតិភូបានជ្រាបអំពីដំណើរការប្រព្រឹត្តទៅរបស់ព្រឹទ្ធសភាកម្ពុជា តួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់គណៈកម្មការទី១០ ព្រឹទ្ធសភាកម្ពុជា។ ជាមួយគ្នានោះ ឯកឧត្តមឧត្តមនារីឯកក៏បានជម្រាបជូនអង្គប្រជុំជ្រាបផងដែរអំពី តួនាទី និងអំណាចរបស់គណៈកម្មការព្រឹទ្ធសភាថៃ មានដូចជា៖១.ពិចារណាធ្វើសេចក្ដីព្រាងច្បាប់ ២.បំពេញកិច្ចការ ពិចារណាស្វែងរកការពិត ឬសិក្សាត្រួតពិនិត្យការប្រព្រឹត្តអំពើពុករលួយ និងការប្រព្រឹត្តល្មើសនៅក្នុងអង្គភាពរបស់រដ្ឋ ឬអង្គភាពផ្សេងៗ ៣.ការពង្រឹងអភិបាលកិច្ចល្អក្នុងការគ្រប់គ្រងការងាររដ្ឋតាមគោលការណ៍ ការគ្រប់គ្រងកិច្ចការក្នុងប្រទេសដែលល្អ និងតាមទស្សនៈសេដ្ឋកិច្ចគ្រប់គ្រាន់ ៤.សិក្សាអំពីរឿងនានាពាក់ព័ន្ធទៅនឹងយន្តការ និងវិធានការការពារ និងបង្ក្រាបអំពើពុករលួយ និងការប្រព្រឹត្តល្មើស ៥.ពិចារណាសិក្សាតាមដានផ្ដល់មតិយោបល់ និងជំរុញការបដិវត្តប្រទេស និងផែនការមេ ក្រោមយុទ្ធសាស្ត្រជាតិដែលមាននៅក្នុងតួនាទី និងអំណាច និងកិច្ចការផ្សេងៗទៀតដែលពាក់ព័ន្ធ៕

(អត្ថបទ៖ គឹម សិទ្ធី រូបភាព៖ គង់ យ៉ារីន)



*គណៈកម្មការទី១០ព្រឹទ្ធសភា ថតរូបអនុស្សាវរីយ៍ជាមួយគណៈប្រតិភូព្រឹទ្ធសភាថៃ*

# គណៈកម្មការទាំង១០ព្រឹទ្ធសភាចូលរួមកិច្ចប្រជុំនានា

❈ឯកឧត្តម **យ៉ង់ សែម** ប្រធានគណៈកម្មការទី១ព្រឹទ្ធសភាបានអញ្ជើញ៖



-ដឹកនាំកិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការទី១ព្រឹទ្ធសភា ដើម្បីត្រៀមជួបសវនាការជាមួយនឹងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងនឹងការជួញដូរ និងក្រសួងកិច្ចការនារី ព្រមទាំងគម្រោងរៀបចំអបអរសាទរទិវាសិទ្ធិមនុស្សអន្តរជាតិ១០ ធ្នូ ឆ្នាំ២០២២ នៅសាលប្រជុំពិសេស៣ព្រឹទ្ធសភា នាថ្ងៃទី ១៩ ខែតុលា ឆ្នាំ២០២២។



-ជាអធិបតីភាពក្នុងកិច្ចប្រជុំត្រៀមចូលរួមកិច្ចប្រជុំអាស៊ានអាយប៉ាលើកទី៤៣ (AIPA) នៅសាលប្រជុំពិសេស៣ព្រឹទ្ធសភា នាថ្ងៃទី២០ ខែតុលា ឆ្នាំ២០២២។

❈ឯកឧត្តម **ខា ខេង** ប្រធានគណៈកម្មការទី២ព្រឹទ្ធសភាបានអញ្ជើញដឹកនាំកិច្ចប្រជុំ៖

-ត្រៀមចូលរួមក្នុងកិច្ចប្រជុំក្រុមការងារទទួលបន្ទុកការសើរើលក្ខន្តិកៈនៃសភាប្រើភាសាបារាំង (APF) នៅសាធារណរដ្ឋបារាំង ចូលរួមមហាសន្និបាតប្រចាំឆ្នាំ នៃបណ្ដាញក្រុមសីលធម៌សមាជិកព្រឹទ្ធសភាប្រើភាសាបារាំង នៅសាធារណរដ្ឋបារាំង និងបំពេញទស្សនកិច្ចការងារនៅសភាសហព័ន្ធវ៉ាឡូនី-ប្រ៊ុចសែល នៃព្រះរាជាណាចក្រប៊ែលហ្ស៊ិក




នៅសាលប្រជុំគណៈកម្មការទី២ព្រឹទ្ធសភា នាព្រឹកថ្ងៃទី៣ ខែតុលា ឆ្នាំ២០២២។



-ពិនិត្យ និងពិភាក្សាលើសេចក្ដីព្រាងកម្មវិធីទស្សនកិច្ចផ្លូវការរបស់គណៈប្រតិភូព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា នៅសាធារណរដ្ឋសង្គមនិយមវៀតណាម នៅសាលប្រជុំពិសេសព្រឹទ្ធសភា នាថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២២។

❈ឯកឧត្តមបណ្ឌិត **ម៉ុង ឫទ្ធី** ប្រធានគណៈកម្មការទី៣ព្រឹទ្ធសភាបានអញ្ជើញដឹកនាំកិច្ចប្រជុំ៖



-ផ្ទៃក្នុងគណៈកម្មការទី៣ព្រឹទ្ធសភា ដើម្បីពិនិត្យ ពិភាក្សាលើសេចក្ដីព្រាងច្បាប់ស្ដីពី ការអនុម័តយល់ព្រមលើពិធីសារទីបួន ស្ដីពីវិសោធនកម្មកិច្ចព្រមព្រៀងវិនិយោគទូលំទូលាយអាស៊ាន នៅសាលប្រជុំពិសេសព្រឹទ្ធសភា នាព្រឹក

ថ្ងៃទី៦ ខែតុលា ឆ្នាំ២០២២។



-អន្តរគណៈកម្មការនានារបស់ព្រឹទ្ធសភាជាមួយតំណាងរាជរដ្ឋាភិបាលដឹកនាំដោយឯកឧត្តម **ជិន ម៉ុនស៊ាន** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស អនុប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដើម្បីពិនិត្យសិក្សាលើសេចក្ដីព្រាងច្បាប់ស្ដីពីការអនុម័តយល់ព្រមលើពិធីសារទីបួន ស្ដីពីវិសោធនកម្មកិច្ចព្រមព្រៀងវិនិយោគទូលំទូលាយអាស៊ាន នៅសាលប្រជុំពិសេសព្រឹទ្ធសភា នារសៀលថ្ងៃទី៦ ខែតុលា ឆ្នាំ២០២២។



❈នាព្រឹកថ្ងៃទី១០ ខែតុលា ឆ្នាំ២០២២ ឯកឧត្តម **សុខ ឥសាន** ប្រធានគណៈកម្មការទី៤ព្រឹទ្ធសភាបានអញ្ជើញដឹកនាំកិច្ចប្រជុំក្រុមសមាជិកព្រឹទ្ធសភា (ក្រុមទី២) ដើម្បីពិនិត្យ ពិភាក្សា និងត្រៀមឱ្យយោបល់លើសេចក្ដីព្រាងច្បាប់ស្ដីពីការអនុម័តយល់ព្រមលើពិធីសារទីបួន ស្ដីពីវិសោធនកម្មកិច្ចព្រមព្រៀងវិនិយោគទូលំទូលាយអាស៊ាន នៅសាលប្រជុំគណៈកម្មការទី៤ព្រឹទ្ធសភា។

❈នាព្រឹកថ្ងៃទី៦ ខែតុលា ឆ្នាំ២០២២ ឯកឧត្តម **អ៊ុក ម៉ុនឈឿន** ប្រធានគណៈកម្មការទី៦ព្រឹទ្ធសភាបានអញ្ជើញដឹកនាំកិច្ចប្រជុំក្រុមសមាជិកព្រឹទ្ធសភា (ក្រុមទី៣) ដើម្បីពិនិត្យ ពិភាក្សា និងត្រៀមឱ្យយោបល់លើសេចក្ដីព្រាងច្បាប់ស្ដីពី ការអនុម័តយល់ព្រមលើពិធីសារទីបួនស្ដីពីវិសោធនកម្មកិច្ចព្រមព្រៀងវិនិយោគទូលំទូលាយអាស៊ាន



នៅសាលប្រជុំគណៈកម្មការទី៦ព្រឹទ្ធសភា។

❈លោកជំទាវ **មាន សំអាន** ប្រធានគណៈកម្មការទី៨ព្រឹទ្ធសភាបានអញ្ជើញដឹកនាំកិច្ចប្រជុំ៖



-ក្រុមសមាជិកាព្រឹទ្ធសភា ដើម្បីពិភាក្សាត្រៀមរៀបចំវេទិកាស្ដីពី ការពង្រឹងសមត្ថភាពដឹកនាំក្នុងការផ្ដល់សេវាសាធារណៈរបស់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ជាស្ត្រី ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្តសៀមរាប ខេត្តឧត្តរមានជ័យ និងខេត្តប៉ៃលិន នៅសាលប្រជុំគណៈកម្មការទី៨ព្រឹទ្ធសភា នាព្រឹកថ្ងៃទី៥ ខែតុលា ឆ្នាំ២០២២។



-ផ្ទៃក្នុងគណៈកម្មការទី៨ព្រឹទ្ធសភា នៅសាលប្រជុំគណៈកម្មការទី៨ព្រឹទ្ធសភា នាព្រឹកថ្ងៃទី៦ ខែតុលា ឆ្នាំ២០២២ ដើម្បីពិនិត្យ ពិភាក្សាលើ៖ ១-ការបូកសរុបលទ្ធផលការងាររបស់គណៈកម្មការទី៨ព្រឹទ្ធសភា ប្រចាំនព្វមាស ឆ្នាំ២០២២ និងទិសដៅការងារបន្ត ២-ការទូទាត់ចំណូល ចំណាយថវិការបស់គណៈកម្មការប្រចាំនព្វមាស

ឆ្នាំ២០២២ និង៣-បញ្ហាផ្សេងៗ។



-ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៦ នៅសាល-ប្រជុំគណៈកម្មការទី៨ព្រឹទ្ធសភា នារសៀលថ្ងៃទី៦ ខែតុលា ឆ្នាំ២០២២ ដើម្បីពិនិត្យ ពិភាក្សាលើ៖ ១-ការបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២២ របស់ក្រុមសមាជិកព្រឹទ្ធ-សភាប្រចាំភូមិភាគទី៦ ២-របាយការណ៍ថវិកាចំណូលចំណាយរបស់ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៦ និង៣-បញ្ហាផ្សេងៗ។



❈នាថ្ងៃទី៧ ខែតុលា ឆ្នាំ២០២២ ឯកឧត្តម **គង់ សារាជ** ប្រធានគណៈកម្មការទី៩ព្រឹទ្ធសភាបានអញ្ជើញជាអធិ-បតីភាពក្នុងកិច្ចប្រជុំក្រុមសមាជិកព្រឹទ្ធសភា (ក្រុមទី៥) ដើម្បីពិនិត្យ ពិភាក្សា និងត្រៀមឱ្យយោបល់លើសេចក្តី-ព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើពិធីសារទីបួនស្តីពីវិសោធនកម្មកិច្ចព្រមព្រៀងវិនិយោគទូលំទូលាយអាស៊ាន និងបញ្ហាផ្សេងៗ នៅសាលប្រជុំគណៈកម្មការទី១០ព្រឹទ្ធសភា។

❈ឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការទី១០ព្រឹទ្ធសភាបានអញ្ជើញដឹកនាំកិច្ចប្រជុំ៖

-ផ្ទៃក្នុងគណៈកម្មការទី១០ព្រឹទ្ធសភា ដើម្បីពិនិត្យលើឯកសារស្តីពី ការត្រៀមជួបពិភាក្សា និងផ្លាស់ប្តូរបទសោធន៍ការងារជាមួយនឹងគណៈប្រតិភូគណៈកម្មការស៊ើបអង្កេតអំពើពុករលួយ ការប្រព្រឹត្តខុស និងពង្រឹងអភិបាលកិច្ចល្អនៃព្រឹទ្ធសភាព្រះរាជាណាចក្រថៃឡង់ដ៍ នៅសាលប្រជុំពិសេស វិមានព្រឹទ្ធសភា នាព្រឹកថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២២។



-ពិភាក្សាការងារជាមួយនឹងលោក **សុខ សំណាង** ជំនួយការសម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធ-សភា នៃព្រះរាជាណាចក្រកម្ពុជា និងជាតំណាងអង្គការ Global Life Sharing ប្រចាំព្រះរាជាណាចក្រកម្ពុជា តំណាងមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត និងក្រុមការងារវិស្វករ ស្តីពីតម្រូវការចាំបាច់នានាក្នុងការបង្កើតមជ្ឈមណ្ឌលស្តារកាយ-សម្បទា សម្តេចតេជោ **ហ៊ុន សែន** នៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត នាព្រឹកថ្ងៃទី២០ ខែតុលា ឆ្នាំ២០២២។

-ផ្ទៃក្នុងគណៈកម្មការទី១០ព្រឹទ្ធសភា ដើម្បីពិនិត្យសម្រេចលើរបាយការណ៍ស្តីពី សកម្មភាព និងលទ្ធផលការងារ របាយការណ៍ថវិការបស់គណៈកម្មការប្រចាំខែតុលា ឆ្នាំ២០២២ នៅសាលប្រជុំគណៈកម្មការទី១០ព្រឹទ្ធ-សភា នាព្រឹកថ្ងៃទី២១ ខែតុលា ឆ្នាំ២០២២។

❈ឯកឧត្តម **ឈិត គីមយាត** អនុប្រធានគណៈកម្មការទី៥ព្រឹទ្ធសភាបានអញ្ជើញដឹកនាំកិច្ចប្រជុំ៖

-គណៈកម្មាធិការរៀបចំ នៃមហាសន្និបាតអន្តរសភាអាស៊ានអាយប៉ាលើកទី៤៣ (Committee on Organization Matters AIPA-43) ដើម្បីពិនិត្យពីវឌ្ឍនភាពការងាររបស់គណៈកម្មាធិការ ដែលប្រទេសកម្ពុជាគ្រោងនឹងធ្វើជាម្ចាស់ផ្ទះ និងបញ្ហាផ្សេងៗ នៅសាលសិក្ខាសាលាខាងជើង វិមាន



ព្រឹទ្ធសភា នារសៀលថ្ងៃទី៤ ខែតុលា ឆ្នាំ២០២២។



-ប្រជុំផ្ទៃក្នុងគណៈកម្មការទី៥ព្រឹទ្ធសភា នៅសាលប្រជុំគណៈកម្មការទី៥ព្រឹទ្ធសភា នាថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២២ ដើម្បីពិនិត្យ ពិភាក្សាលើ៖ **១**-ការបូកសរុបលទ្ធផលការងាររបស់គណៈកម្មការទី៥ព្រឹទ្ធសភា ប្រចាំខែតុលា ឆ្នាំ២០២២ **២**-ការពិនិត្យខ្លឹមសារសំខាន់ៗ កម្រងសំណួរ ព្រមទាំងសំណូមពរនានារវាងគណៈកម្មការទី៥ព្រឹទ្ធសភាជួបជាមួយនឹងក្រសួងព័ត៌មាន នាថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២២ខាងមុខ **៣**-ការពិនិត្យផែនការប្រតិបត្តិរបស់គណៈកម្មការប្រចាំឆ្នាំ២០២៣ **៤**-បិទបញ្ជីចំណូល-ចំណាយថវិកាប្រចាំនព្វ-មាស (រយៈពេល៩ខែ) ឆ្នាំ២០២២ និង**៥**-បញ្ហាផ្សេងៗ។

❋នាព្រឹកថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២២ ឯកឧត្តម **ប្រាក់ ចំរើន** អនុប្រធានគណៈកម្មការទី៨ព្រឹទ្ធសភាបានអញ្ជើញជួបជាមួយថ្នាក់ដឹកនាំនៃអគ្គនាយកដ្ឋានពិធីការ និងទំនាក់-ទំនងអន្តរជាតិ ដើម្បីពិនិត្យលើឯកសារត្រៀមចូលរួមកិច្ច-ប្រជុំប្រចាំឆ្នាំ នៃវេទិកាសភាអាស៊ី-ប៉ាស៊ីហ្វិកលើកទី៣០ (APPF-30) នៅទីក្រុងបាងកក ប្រទេសថៃ នៅសាលប្រជុំគណៈកម្មការទី៨ព្រឹទ្ធសភា៕

## ការទទួលពាក្យបណ្ដឹង

❋នៅខែតុលា ឆ្នាំ២០២២ ព្រឹទ្ធសភាបានទទួលពាក្យបណ្ដឹងចំនួន៤ករណី បញ្ជូនពាក្យបណ្ដឹងទៅក្រសួង រាជធានី ខេត្ត និងស្ថាប័នពាក់ព័ន្ធចំនួន៣ករណី ទទួលលិខិតឆ្លើយតបពីការដោះស្រាយពីស្ថាប័នពាក់ព័ន្ធចំនួន១ករណី កំពុងពិនិត្យសិក្សាចំនួន៧ករណី (សល់ពីខែមុន២ករណី)៕

## សមាជិក សមាជិកាព្រឹទ្ធសភាបំពេញបេសកកម្មក្រៅប្រទេស

❋ចាប់ពីថ្ងៃទី១៤ ខែតុលា ដល់ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២២ ឯកឧត្ដមបណ្ឌិត **ម៉ុង ឫទ្ធី** ប្រធានគណៈកម្មការទី៣ព្រឹទ្ធសភាបានអញ្ជើញបំពេញទស្សនកិច្ចនៅសមាគមសណ្ដែកសៀងអាមេរិក និងចូលរួមកម្មវិធីពានរង្វាន់ស្បៀងអាហារពិភពលោក នៅរដ្ឋអៃយ៉ូវ៉ា សហរដ្ឋអាមេរិក។

❋ចាប់ពីថ្ងៃទី៩ ដល់ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២២ លោកជំទាវ**ឃួន ឃុនឌី** សមាជិកាគណៈកម្មការទី៥ព្រឹទ្ធសភាបានអញ្ជើញចូលរួមមហាសន្និបាតសហភាពអន្តរ-




សភាលើកទី១៤៥ (IPU-145) និងកិច្ចប្រជុំពាក់ព័ន្ធនានា នៅទីក្រុងKigali នៃសាធារណរដ្ឋរវ៉ាន់ដា (Rwanda)៕

# សមាជិក សមាជិកាព្រឹទ្ធសភាបំពេញការងារនៅតាមបណ្តាភូមិភាគទាំង៨

✿ឯកឧត្តម **យ៉ង់ សែម** ប្រធានគណៈកម្មការទី១ព្រឹទ្ធសភា បានអញ្ជើញចូលរួម៖

-ពិធីបុណ្យភ្ជុំបិណ្ឌ និងនាំយកនូវទេយ្យទាន ព្រមទាំងបច្ច័យមួយចំនួនប្រគេនព្រះសង្ឃគង់នៅវត្តរកាកណ្តាល សង្កាត់រកាកណ្តាល ក្រុងក្រចេះ ខេត្តក្រចេះ នាថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២២។

-ជាកិត្តិយសក្នុងទិវាមនុស្សចាស់កម្ពុជា និងទិវាមនុស្សចាស់អន្តរជាតិ ក្រោមអធិបតីភាពឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **អ៊ឹម ឈុនលឹម** ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ នៅសង្កាត់រកាកណ្តាល ក្រុងក្រចេះ ខេត្តក្រចេះ នាថ្ងៃទី១ ខែតុលា ឆ្នាំ២០២២។

✿ឯកឧត្តម **ខាវ ខេង** ប្រធានគណៈកម្មការទី២ព្រឹទ្ធសភាបានអញ្ជើញ៖



-ជួបសំណេះសំណាល និងពិសាអាហារសាមគ្គីជាមួយនឹងអតីតសិស្សានុសិស្សនៅវិទ្យាល័យសន្តិភាព (បច្ចុប្បន្នមន្ទីរអប់រំខេត្តកំពង់ស្ពឺ) នៅខេត្តកំពង់ស្ពឺ នាថ្ងៃទី២ ខែតុលា ឆ្នាំ២០២២។



-ជាអធិបតីភាពក្នុងវគ្គបណ្តុះបណ្តាលស្តីពី ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតឆ្នាំ២០២៣ មកពីខណ្ឌចំនួន៧ រួមមាន៖ ខណ្ឌដង្កោ ខណ្ឌមានជ័យ ខណ្ឌទួលគោក ខណ្ឌព្រែកព្នៅ ខណ្ឌបឹងកេងកង ខណ្ឌពោធិ៍សែនជ័យ និងខណ្ឌជ្រោយចង្វារ សរុបចំនួន២៨៦នាក់ នៅរាជធានីភ្នំពេញ នាថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២២។

✿ឯកឧត្តមបណ្ឌិត **ម៉ុង ឫទ្ធី** ប្រធានគណៈកម្មការទី៣ព្រឹទ្ធសភាបានអញ្ជើញ៖

-ជួបសំណេះសំណាល សួរសុខទុក្ខ និងណែនាំដល់កម្មករអំពីរបៀបថែទាំដំណាំផ្សេងៗ ព្រមទាំងពិនិត្យមើលទំនប់ទឹក ហេដ្ឋារចនាសម្ព័ន្ធនានា ព្រមទាំងជួបសំណេះ-សំណាល សួរសុខទុក្ខប្រជាពលរដ្ឋមកសម្រាកកម្សាន្តនៅតំបន់អភិវឌ្ឍន៍ម៉ុង ឫទ្ធី សែនជ័យ និងចែកជូនថវិកាមួយចំនួនដល់កុមារា កុមារី នៅភ្នំសែនជ័យ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២២។

-ជួបសំណេះសំណាល និងសួរសុខទុក្ខ ព្រមទាំងប្រមូលផលផ្លែដូងចែកជូនកម្មករ នៅភ្នំសែនជ័យ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាថ្ងៃទី១ ខែតុលា ឆ្នាំ២០២២។

-ជួបសំណេះសំណាល និងសួរសុខទុក្ខកម្មករ ព្រមទាំងចុះដឹកនាំក្រុមការងារបច្ចេកទេសសំណង់ កសិកម្ម និងផ្នែកថែទាំសត្វព្រៃ ដើម្បីពិនិត្យកែលម្អឡើងវិញទីកន្លែងចិញ្ចឹមសត្វព្រៃឱ្យមានផាសុកភាព នៅភ្នំសែនជ័យ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាថ្ងៃទី៣ ខែតុលា ឆ្នាំ២០២២។

-ជួបសំណេះសំណាល និងសួរសុខទុក្ខកម្មករ ព្រមទាំងចុះពិនិត្យមើលទំនប់ទឹក និងចុះពិនិត្យមើលទីតាំងដីសម្រាប់ត្រៀមដាំកូនដើមឈើប្រណិតចំនួន៥០.០០០ដើមបន្ថែមទៀត នៅភ្នំសែនជ័យ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាថ្ងៃទី៨ ខែតុលា ឆ្នាំ២០២២។

✿នាព្រឹកថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២២ ឯកឧត្តម **សុខ ឥសាន** ប្រធានគណៈកម្មការទី៤ព្រឹទ្ធសភាបានអញ្ជើញជួបសំណេះសំណាល និងពិភាក្សាការងារជាមួយនឹងសមាជិកក្រុមប្រឹក្សាឃុំទាំងអស់ នៃស្រុកកំពង់ត្របែក ខេត្តព្រៃវែង។

✿នាថ្ងៃទី៨ ខែតុលា ឆ្នាំ២០២២ ឯកឧត្តម **អ៊ុក ប៊ុនឈឿន** ប្រធានគណៈកម្មការទី៦ព្រឹទ្ធសភាបានអញ្ជើញជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាឃុំអំពីតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ និងការផ្តល់សេវាធារណៈ

ជូនប្រជាពលរដ្ឋក្នុងមូលដ្ឋាន នៅស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ។



❈នាថ្ងៃទី៤ ខែតុលា ឆ្នាំ២០២២ ឯកឧត្តម **ម៉ុម ឌឹមហ៊ុយ** ប្រធានគណៈកម្មការទី៧ព្រឹទ្ធសភា និងឯកឧត្តម **ម៉ាន់ ឈឿន** អនុប្រធានគណៈកម្មការទី៧ព្រឹទ្ធសភាបានអញ្ជើញជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាសង្កាត់ និងប្រជាការពារ នៅសង្កាត់វាលស្បូវ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ដើម្បីស្តាប់របាយការណ៍រួមក្នុងមូលដ្ឋាន ព្រមទាំងឧបត្ថម្ភថវិកាមួយចំនួន។

❈ឯកឧត្តម **ម៉ុម ឌឹមហ៊ុយ** ប្រធានគណៈកម្មការទី៧ព្រឹទ្ធសភាបានអញ្ជើញ៖



-ជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាសង្កាត់ និងនាយប៉ុស្តិ៍នគរបាលរដ្ឋបាល នៅសង្កាត់ប្រទះឡាង ខណ្ឌកំបូល រាជធានីភ្នំពេញ ដើម្បីស្តាប់របាយការណ៍រួមក្នុងមូលដ្ឋាន ព្រមទាំងឧបត្ថម្ភថវិកាមួយចំនួន នាថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២២។

-ដឹកនាំក្រុមប្រឹក្សាសង្កាត់ និងស្មៀន សង្កាត់ស្នោរ ខណ្ឌកំបូល រាជធានីភ្នំពេញ ទៅធ្វើទស្សនកិច្ចផ្លូវល្បឿនលឿនភ្នំពេញ-ក្រុងព្រះសីហនុ ដើម្បីពិនិត្យមើលវឌ្ឍនភាព និងការអភិវឌ្ឍរបស់ប្រទេស ក្រោមការដឹកនាំដ៏ត្រឹមត្រូវ និងឈ្លាសវៃប្រកបដោយគតិបណ្ឌិតរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នាថ្ងៃទី១៣



ខែតុលា ឆ្នាំ២០២២។



-ជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សា និងមន្ត្រីការិយាល័យបោះឆ្នោត នៅសាលាសង្កាត់បឹងធំ ខណ្ឌកំបូល រាជធានីភ្នំពេញ ដើម្បីស្តាប់របាយការណ៍រួមក្នុងមូលដ្ឋាន និងដំណើរការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតឆ្នាំ២០២៣ ព្រមទាំងឧបត្ថម្ភថវិកាមួយចំនួន នាថ្ងៃទី២២ ខែតុលា ឆ្នាំ២០២២។



❈នារសៀលថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២២ លោកជំទាវ **មាន សំអាន** ប្រធានគណៈកម្មការទី៨ព្រឹទ្ធសភាបានអញ្ជើញជួបសំណេះសំណាល និងនាំយកអំណោយចែកជូនប្រជាពលរដ្ឋដែលកំពុងជួបការលំបាកចំនួន២០០គ្រួសារ មកពីស្រុកកំពង់សៀម និងក្រុងកំពង់ចាម ខេត្តកំពង់ចាម ដោយក្នុងមួយគ្រួសារៗទទួលបាន៖ អង្ករ៥គីឡូក្រាម មី១កេស ទឹកត្រី១ដប ប៊ីចេង១កញ្ចប់ ស្ករ-ស១គីឡូក្រាម ម្សៅធ្វើនំបាញ់ឆែវ១កញ្ចប់ ទឹកដោះគោ១កំប៉ុង

ត្រី១កំប៉ុង ថ្នាំដុសធ្មេញ១ប្រអប់ ច្រាសដុសធ្មេញ១ដើម នំបញ្ចុកក្រៀម១កញ្ចប់ ព្រមទាំងថវិកាមួយចំនួន នៅវត្តខេមរ៉ែន ស្ថិតក្នុងសង្កាត់សំបួរមាស ក្រុងកំពង់ចាម ខេត្តកំពង់ចាម។

❈ឯកឧត្តម **គង់ សារាជ** ប្រធានគណៈកម្មការទី៩ ព្រឹទ្ធសភាបានអញ្ជើញ៖

-ជួបពិភាក្សាការងារជាមួយនឹងថ្នាក់ដឹកនាំខេត្ត និងយុវជនតាមបណ្តាស្រុក ក្រុង ដើម្បីផ្តល់បទពិសោធន៍ល្អៗ និងជាគ្រឹះដើម្បីយកទៅបណ្តុះបណ្តាលដល់យុវជនបន្តវេននៅថ្ងៃខាងមុខ ជាពិសេសក្នុងគោលបំណងជំរុញផ្សព្វផ្សាយជូនប្រជាពលរដ្ឋទៅពិនិត្យបញ្ជីឈ្មោះបោះឆ្នោត និងចុះឈ្មោះបោះឆ្នោត នៅខេត្តពោធិ៍សាត់ នាថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២២។

-ជួបពិភាក្សាការងារជាមួយនឹងប្រធានមន្ទីរសុខាភិបាលខេត្តពោធិ៍សាត់ ក្នុងការត្រៀមផ្តល់ថ្នាំពេទ្យ ជូនប្រជាពលរដ្ឋក្រីក្រ ដែលជាអំណោយរបស់សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា នៅខេត្តពោធិ៍សាត់ នាថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២២។

-ជួបពិភាក្សាការងារជាមួយនឹងថ្នាក់ដឹកនាំខេត្ត ព្រមទាំងបន្តចុះពិនិត្យស្ថានភាពរងគ្រោះទឹកជំនន់នៅតាមភូមិ ឃុំ សង្កាត់មួយចំនួនក្នុងខេត្តពោធិ៍សាត់ នាថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២២។

❈នាថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២២ ឯកឧត្តម **ឈួន ឡេង** អនុប្រធានគណៈកម្មការទី២ព្រឹទ្ធសភាបានអញ្ជើញចូលរួមប្រជុំបូកសរុបលទ្ធផលការងាររបស់ស្រុកពាមជរប្រចាំខែតុលា និងលើកទិសដៅការងារបន្ត នៅសាលាស្រុកពាមជរ ខេត្តព្រៃវែង។

❈នាថ្ងៃទី៨ ខែតុលា ឆ្នាំ២០២២ ឯកឧត្តម **ចាន់ណារ៉េត** អនុប្រធានគណៈកម្មការទី៣ព្រឹទ្ធសភា ឯកឧត្តម **ប៉ុល លឹម** អនុប្រធានគណៈកម្មការទី៤ព្រឹទ្ធសភា បានអញ្ជើញចូលរួមក្នុងពិធីកាត់ខ្សែបូសម្ពោធដាក់ឱ្យប្រើប្រាស់វេទិកាអុំទូក ខេត្តបាត់ដំបង និងផ្តល់អំណោយជូនដល់កម្មករចំនួន២៥០នាក់ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅវេទិកាអុំទូកខេត្តបាត់ដំបង ភូមិព្រែកមហាទេព សង្កាត់ស្វាយប៉ោ ក្រុងបាត់ដំបង ខេត្តបាត់ដំបង។

❈នាថ្ងៃទី៩ ខែតុលា ឆ្នាំ២០២២ ឯកឧត្តម **អោយ ខន** អនុប្រធានគណៈកម្មការទី៦ព្រឹទ្ធសភាបានអញ្ជើញចូលរួមកម្មវិធីផ្សព្វផ្សាយផែនការរួមឆ្ពោះទៅកាន់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ នៃរដ្ឋសភា ឆ្នាំ២០២៣ នៅសាលាខេត្តកោះកុង ខេត្តកោះកុង។

❈ឯកឧត្តម **ម៉ាន់ ឈឿន** អនុប្រធានគណៈកម្មការទី៧ព្រឹទ្ធសភាបានអញ្ជើញ៖



-ចូលរួមប្រជុំជាមួយនឹងក្រុមប្រឹក្សាសង្កាត់ទឹកល្អក់ទី២ និងមេភូមិទាំង១៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ ដើម្បីពិនិត្យលទ្ធផលការងារខែកញ្ញា និងលើកទិសដៅការងារខែតុលា ឆ្នាំ២០២២ ព្រមទាំងធ្វើបច្ចុប្បន្នភាពអ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោតឆ្នាំ២០២១ និងត្រៀមសម្រាប់ការចុះឈ្មោះបោះឆ្នោតឆ្នាំ២០២៣ និងឧបត្ថម្ភថវិកាដល់សមាគមការពារថែទាំសុខភាពមនុស្សចាស់ នាថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២២។



-ចុះសួរសុខទុក្ខលោក **ផុន សារ៉ន** អតីតសមាជិកក្រុមប្រឹក្សាសង្កាត់ទឹកល្អក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ដែលកំពុងសម្រាកថែទាំសុខភាពនៅគេហដ្ឋាន និងបានជួយសម្រាលការខ្វះខាតដល់លោកស្រី **កន ណាវី** មន្ត្រីជាប់កិច្ចសន្យាសាលាសង្កាត់ ព្រមទាំងឧបត្ថម្ភអង្ករ ត្រីខ មី ម៉ាស់ ទឹកដែលសម្អាតដៃ កន្សែងពោះគោ និងថវិកាមួយចំនួន នាថ្ងៃទី៧ ខែតុលា ឆ្នាំ២០២២។

-ចូលរួមប្រជុំជាមួយគណៈបញ្ជាការឯកភាពសង្កាត់



ទឹកល្អក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ នាថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២២ ដើម្បីបែងចែកភារកិច្ចការងារក្នុងការបង្ក្រាបល្បែងស៊ីសង និងទីតាំងបញ្ចាំខុសច្បាប់ រៀបចំសណ្តាប់ធ្នាប់តាមដងផ្លូវ ធ្វើបញ្ជីស្ថិតិអ្នកគ្រប់អាយុ១៨ឆ្នាំ បច្ចុប្បន្នភាពអត្តសញ្ញាណកម្មគ្រួសារក្រីក្រ និងខិតខំបង្កើនប្រសិទ្ធភាព ការងារច្រកចេញចូលតែមួយរបស់សង្កាត់ឱ្យកាន់តែប្រសើរ។



-ជួបសំណេះសំណាល ព្រមទាំងឧបត្ថម្ភអង្ករ និងកន្សែងពោះគោជូនដល់មន្ត្រីកងកម្លាំងសន្តិសុខ និងមន្ត្រីផ្នែកអនាម័យ ស្ថិតនៅសង្កាត់អូរបែកក្អម ខណ្ឌសែនសុខ រាជធានីភ្នំពេញ នាថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២២។



-ជួបសំណេះសំណាល សួរសុខទុក្ខលោកយាយ និងជនពិការ ព្រមទាំងឧបត្ថម្ភអង្ករ និងថវិកាមួយចំនួន ដែលរស់នៅភូមិ៤ សង្កាត់ទឹកល្អក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ នាថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២២។



-ចូលរួមជាមួយប្រធានភូមិទាំង១៣ និងប្រជាពលរដ្ឋបើកការដ្ឋានជួសជុលអ៊ុតកៅស៊ូអាស់ស្វាល់ ផ្លូវលេខ១៥០ ប្រវែង៣៧៨ម៉ែត្រ ស្ថិតនៅភូមិ៥ សង្កាត់ទឹកល្អក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ នាថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២២។



❈នាថ្ងៃទី២១ ខែតុលា ឆ្នាំ២០២២ ឯកឧត្តម **ម៉ាន់ ឈឿន** អនុប្រធានគណៈកម្មការទី៧ព្រឹទ្ធសភា និងលោកជំទាវ **មុំ សណ្ដាប់** លេខាធិការគណៈកម្មការទី៨ព្រឹទ្ធសភា បានអញ្ជើញចូលរួមអង្គកឋិនទានរៀបចំដោយសាលាក្រុងភ្នំពេញ ដើម្បីដង្ហែទៅវេរប្រគេនព្រះសង្ឃដែលគង់ចាំព្រះវស្សាអស់ត្រីមាស ក្នុងពុទ្ធសីមា នៅវត្តប្រសិទ្ធីរម្មារាម ស្ថិតក្នុងសង្កាត់ពន្សាំង ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ។



❈នាព្រឹកថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២២ ឯកឧត្តម **ច្រាក់ ចំរើន** អនុប្រធានគណៈកម្មការទី៨ព្រឹទ្ធសភាបានអញ្ជើញចុះសួរសុខទុក្ខ និងចូលរួមរំលែកទុក្ខជាមួយនឹងក្រុមគ្រួសារ

សពកុមារទាំង១១នាក់ ដែលបាត់បង់ជីវិតក្នុងឧបទ្ទវហេតុលិចទូកចម្លងកាលពីរសៀលថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២២ ព្រមទាំងឧបត្ថម្ភថវិកាមួយចំនួនដល់គ្រួសារសព គ្រួសាររងគ្រោះ កងកម្លាំង និងអាជ្ញាធរ ស្ថិតក្នុងភូមិកោះចំរើន ឃុំកំពង់ភ្នំ ស្រុកលើកដែក ខេត្តកណ្ដាល។



❋នាថ្ងៃទី២ ខែតុលា ឆ្នាំ២០២២ ឯកឧត្តម **ម៉ែន-ស៊ីផាន់** អនុប្រធានគណៈកម្មការទី៩ព្រឹទ្ធសភាបានអញ្ជើញជួបសំណេះសំណាលពិភាក្សាការងារជាមួយនឹងក្រុមប្រឹក្សាឃុំ ប្រធានភូមិ មន្ត្រីពាក់ព័ន្ធ ព្រមទាំងឧបត្ថម្ភថវិកាមួយចំនួនដល់រដ្ឋបាលឃុំ និងចូលរួមរំលែកទុក្ខក្រុម-គ្រួសារសពចំនួន៣គ្រួសារនូវថវិកាមួយចំនួន នៅឃុំព្រះ-ពន្លា ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង។

❋ឯកឧត្តម **ហែម ខន** អនុប្រធានគណៈកម្មការទី១០ព្រឹទ្ធសភាបានអញ្ជើញ៖



-ចូលរួមក្នុងពិធីបូជាសពឧបាសិកា **ទឹម អ៊ីន** ជំនួយការផ្ទាល់សម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រធានព្រឹទ្ធ-សភា នៅភូមិស្វាយក្រវ៉ាន់ សង្កាត់ស្វាយក្រវ៉ាន់ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ នាថ្ងៃទី២ ខែតុលា ឆ្នាំ២០២២។

-ចូលរួមក្នុងពិធីបុណ្យកឋិនទាន នៅវត្តអង្គសិម្ពលី ស្ថិតក្នុងឃុំពើក ស្រុកអង្គស្នួល ខេត្តកណ្ដាល ព្រមទាំងចូលរួមក្នុងពិធីបុណ្យខួបគម្រប់១ឆ្នាំ ដើម្បីឧទ្ទិសកុសលជូនឧបា-សិកា **ឈឹម សើរ** នៅបុរីឈូកមាស សង្កាត់ក្រាំងធ្នង់ ខណ្ឌសែនសុខ រាជធានីភ្នំពេញ នារសៀលថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២២។

❋នាថ្ងៃទី៥ ខែតុលា ឆ្នាំ២០២២ ឯកឧត្តម **ណាំ ទុំ** លេខាធិការគណៈកម្មការទី១ព្រឹទ្ធសភាបានអញ្ជើញជាវាគ្មិនក្នុងសិក្ខាសាលាប្រវត្តិសាស្រ្តយោធាស្ដីពី ការរៀបចំពិនិត្យខ្លឹមសារអនុវត្តនយោបាយ ឈ្នះ ឈ្នះ ក្នុងទិសយោធភូមិភាគទី៥ នៅសាលប្រជុំទីបញ្ជាការយោធភូមិភាគទី៥ ខេត្តបាត់ដំបង ។




❋នាថ្ងៃទី២០ ខែតុលា ឆ្នាំ២០២២ លោកជំទាវ **ភេខ សៅរ៍ធន** លេខាធិការគណៈកម្មការទី៣ព្រឹទ្ធសភាបានអញ្ជើញចូលរួមជាវាគ្មិនក្នុងវេទិកាស្ដីពី “យុទ្ធនាការនារីវ័យក្មេងឆ្ពោះទៅភាពជាអ្នកដឹកនាំ (Girl2Leader)” ក្រោមអធិបតីភាពលោកជំទាវ **ឡោក ខេង** ប្រធានគណៈកម្មការទី៨ នៃរដ្ឋសភា នៅវិទ្យាល័យកំពត ក្រុងកំពត។

❋ឯកឧត្តម **អន ស៊ុំ** លេខាធិការគណៈកម្មការទី៤ព្រឹទ្ធសភា និងឯកឧត្តម **ឈើយ ចាន់ណា** លេខាធិការគណៈកម្មការទី៧ព្រឹទ្ធសភាបានអញ្ជើញ៖



-ជួបសំណេះសំណាលជាមួយនឹងសមាជិកក្រុមប្រឹក្សា-ឃុំទាំង៨ ក្នុងស្រុកស្វាយចេក ដើម្បីស្ដាប់របាយការណ៍ស្ដីពីស្ថានភាពទូទៅ នៃការអភិវឌ្ឍមូលដ្ឋាន នៅសាលាស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ នាថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២២។



-ជួបសំណេះសំណាល និងសួរសុខទុក្ខសមាជិកក្រុម-ប្រឹក្សាឃុំទាំង៦ ក្នុងស្រុកម៉ាឡៃ ដើម្បីស្តាប់របាយការណ៍ស្តីពីស្ថានភាពទូទៅ នៃការអភិវឌ្ឍមូលដ្ឋាន នៅសាលាស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ នាថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២២។



-ជួបសំណេះសំណាល និងសួរសុខទុក្ខសមាជិក ក្រុម-ប្រឹក្សាសង្កាត់ទាំង៥ ក្នុងក្រុងប៉ោយប៉ែត ដើម្បីស្តាប់របាយ-ការណ៍ស្តីពី ស្ថានភាពទូទៅ នៃការអភិវឌ្ឍមូលដ្ឋាន នៅសាលាក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ នាថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២២។



-ជួបសំណេះសំណាល និងសួរសុខទុក្ខសមាជិក សមា-ជិកាក្រុមប្រឹក្សាឃុំទាំង៧ ដើម្បីស្តាប់របាយការណ៍ស្តីពីស្ថានភាពទូទៅ នៃការអភិវឌ្ឍមូលដ្ឋាន នៅសាលាស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ នាថ្ងៃទី២០ ខែតុលា ឆ្នាំ២០២២។




-សំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ មន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅសាលាខេត្តបន្ទាយមានជ័យ នាថ្ងៃទី២២ ខែតុលា ឆ្នាំ២០២២។



-សំណេះសំណាល និងចែកស្រូវពូជ ជូនប្រជាពលរដ្ឋដែលរងផលប៉ះពាល់ដោយទឹកជំនន់ទឹកភ្លៀង ក្រោមអធិ-បតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅផ្សារបូរីជ័យ២ ឃុំឫស្សីក្រោក ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ នាថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២២។

❋ឯកឧត្តម **ឆាយ ឫទ្ធិសែន** លេខាធិការគណៈកម្មការទី៥ព្រឹទ្ធសភាបានអញ្ជើញ៖



-ចូលរួមជាគណៈអធិបតីភាពក្នុងពិធីប្រគល់ពានរង្វាន់

អបអរសន្តិភាពប៉ើសខ២ ដែលរៀបចំការប្រកួតនៅភូមិទួលសម្បត្តិ ឃុំប៉ើសខ២ ស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ នាថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២២។



-ជួបសំណេះសំណាល និងសួរសុខទុក្ខ ព្រមទាំងនាំយកអំណោយមនុស្សធម៌ រួមមាន៖ មី ទឹកត្រី ទឹកស៊ីអ៊ីវ ប្រេងឆា ទឹកដោះគោ ស្ករ-ស ចែកជូនដល់បងប្អូនប្រជាពលរដ្ឋសាសនិកឥស្លាមដែលកំពុងមានជំងឺ និងមានជីវភាពខ្វះខាត នៅភូមិព្រែកតាពៅ សង្កាត់ព្រែកប្រា ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ នាថ្ងៃទី៤ ខែតុលា ឆ្នាំ២០២២។

❈នាថ្ងៃទី៩ ខែតុលា ឆ្នាំ២០២២ ឯកឧត្តម **គឹម ឆា** លេខាធិការគណៈកម្មការទី៦ព្រឹទ្ធសភាបានអញ្ជើញចូលរួមបុណ្យសពលោក **ទេព ឆន់** អតីតប្រធានមន្ទីរធម្មការ និងសាសនា ខេត្តស្វាយរៀង ព្រមទាំងឧបត្ថម្ភ រួមមាន៖ អង្ករ មី ទឹកត្រី ទឹកស៊ីអ៊ីវ ទឹកផ្លែឈើ ទឹកបរិសុទ្ធ និងថវិកាមួយចំនួន នៅភូមិលៀប ឃុំកណ្តៀងរាយ ស្រុកស្វាយទាប ខេត្តស្វាយរៀង។

❈ឯកឧត្តម **ឈើយ ចាន់ណា** លេខាធិការគណៈកម្មការទី៧ព្រឹទ្ធសភាបានអញ្ជើញ៖



-ជាអធិបតីភាពក្នុងពិធីប្រកាសទទួលស្គាល់សេចក្តីសម្រេច ស្តីពីការតែងតាំងគណៈកម្មាធិការប្រតិបត្តិសាខាសមាគមមូនិធិមនុស្សចាស់ នៅវត្តវេឡុវនោទ្យាន (វត្តស្វាយចេក) ស្ថិតក្នុងឃុំស្វាយចេក ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ នាថ្ងៃទី១ ខែតុលា ឆ្នាំ២០២២។



-ជួបសំណេះសំណាល និងសួរសុខទុក្ខក្រុមប្រឹក្សាឃុំ ដើម្បីពិនិត្យពន្យល់ណែនាំការធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះប្រជាពលរដ្ឋក្នុងភូមិ ឃុំ តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានវិទ្យា នៅសាលប្រជុំស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ នាថ្ងៃទី៧ ខែតុលា ឆ្នាំ២០២២។



-ជាអធិបតីភាពក្នុងពិធីប្រកាសទទួលស្គាល់សេចក្តីសម្រេច ស្តីពីការតែងតាំងគណៈកម្មាធិការប្រតិបត្តិសាខាសមាគមមូលនិធិមនុស្សចាស់ស្រុក នៅសាលប្រជុំសាលាស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ នាថ្ងៃទី៩ ខែតុលា ឆ្នាំ២០២២។



-ជាអធិបតីភាពក្នុងពិធីប្រគល់ពានរង្វាន់បាល់ទាត់ U13 ដល់ក្រុមកីឡាករជ័យលាភី នៅទីលានបាល់ទាត់ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ នាថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២២។

❋លោកជំទាវ **ម៉ុំ សណ្ដាប់** លេខាធិការគណៈកម្មការទី៨ព្រឹទ្ធសភាបានអញ្ជើញ៖

-ជួបក្រុមប្រឹក្សាសង្កាត់ផ្សារដើមថ្កូវ ដើម្បីជំរុញការធ្វើផែនការចុះសំណេះសំណាល និងចុះសួរសុខទុក្ខប្រជាពលរដ្ឋនៅតាមសង្កាត់ ក្នុងខណ្ឌទួលគោក រាជធានីភ្នំពេញ នារសៀលថ្ងៃទី១១ ខែតុលា ឆ្នាំ២០២២។

-ចូលរួមវេទិកាពិគ្រោះយោបល់ស្ដីពី តម្រូវការសេវាសង្គមរបស់ (គ.ក.ស.ក) នៃក្រុមប្រឹក្សារាជធានីភ្នំពេញ អាណត្តិទី៣ និងសួរសុខទុក្ខជនចាស់ជរា អបអរសាទរទិវាមនុស្សចាស់កម្ពុជា និងមនុស្សចាស់អន្តរជាតិ ១ តុលា នៅរាជធានីភ្នំពេញ នាថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២២។

-ជួបសំណេះសំណាលជាមួយនឹងប្រធាន អនុប្រធានភូមិចំនួន២៨នាក់ និងក្រុមយុវជនសង្កាត់ចំនួន២៦នាក់ នៅសង្កាត់ផ្សារដើមថ្កូវ ខណ្ឌទួលគោក រាជធានីភ្នំពេញ នាថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២២ ។



❋នាថ្ងៃទី២ ខែតុលា ឆ្នាំ ២០២២ ឯកឧត្ដម **ឌឹម លាច** សមាជិកគណៈកម្មការទី១ព្រឹទ្ធសភា និងលោកជំទាវ **ស៊ី វណ្ណថា** សមាជិកាគណៈកម្មការទី៩ព្រឹទ្ធសភាបានអញ្ជើញជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាឃុំ គណៈភូមិទាំង១០ និងនាយកសាលារៀន លោកប្រធានមណ្ឌលសុខភាព លោកប្រធានប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ ដើម្បីឈ្វេងយល់ពីភូមិឃុំមានសុវត្ថិភាព ការចុះឈ្មោះបោះឆ្នោត និងបញ្ហាមួយចំនួនដែលមានក្នុងឃុំ ព្រមទាំងឧបត្ថម្ភថវិកាមួយចំនួន នៅឃុំត្រពាំងគរ ស្រុកជើងព្រៃ ខេត្តកំពង់ចាម។

❋ឯកឧត្ដម **ញ៉ែប សុខ** សមាជិកគណៈកម្មការទី២ព្រឹទ្ធសភាបានអញ្ជើញ៖

-ចូលរួមក្នុងពិធីបុណ្យភ្ជុំបិណ្ឌ និងនាំយកចង្ហាន់បិណ្ឌបាត សម្ភារ បរិក្ខារ ព្រមទាំងបច្ច័យបួនមួយចំនួនប្រគេនព្រះពោធិវង្សាវិមល ព្រះមេគណខេត្តខាងគណៈមហានិកាយ និងប្រគេនព្រះមេគណខាងគណៈធម្មយុត្តិកនិកាយដែលគង់នៅវត្តកែវវិជ័យ ស្រុកកណ្ដៀង និងវត្តលលកសថ្មី ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់ នាព្រឹកថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២២។

-នាំយកគ្រឿងឧបភោគបរិភោគ រួមមាន៖ មី ទឹកត្រី ទឹកស៊ីអ៊ីវ ស្ករ-ស ខ្ទឹមស ប្រេងឆា ទៅសួរសុខទុក្ខប្រជាពលរដ្ឋដែលទទួលរងនូវការលិចលង់ផ្ទះសំបែង និងស្រែស្រូវចំនួន៣០គ្រួសារ ដោយសារជំនន់ទឹកភ្លៀងស្ទឹងពោធិ៍សាត់ នៅភូមិបឹងឈូក ឃុំអន្លង់វិល ស្រុកកណ្ដៀង ខេត្តពោធិ៍សាត់ នាថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២២។

-ចូលរួមដង្ហែអង្គកឋិនទានប្រគេនព្រះសង្ឃដែលគង់ចាំព្រះវស្សាអស់ត្រីមាស នៅវត្តឯកសទ្ធា ហៅវត្តអារ៉ែងព្រួច ស្ថិតក្នុងឃុំអន្សាចំបក់ ស្រុកក្រគរ ខេត្តពោធិ៍សាត់ នាថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២២។

❋ឯកឧត្ដម **ច្រឹង គឹមស្រ៊ាន** សមាជិកគណៈកម្មការទី៣ព្រឹទ្ធសភាបានអញ្ជើញចូលរួមក្នុងពិធី៖

-តាំងពិព័រណ៍ផលិតផលកសិកម្ម កសិ-ឧស្សាហកម្ម ផលិតផលកែច្នៃ សិប្បកម្ម សហគ្រាសខ្នាតតូច ព្រមទាំងបានឧបត្ថម្ភថវិកាមួយចំនួនដល់មន្ត្រីសាលាស្រុក និងឧបត្ថម្ភទូក-ងព្រះអណ្ដូងសែនជ័យ នៅស្រុកស្ទឹងត្រង់ និងស្រុកកោះសូទិន ខេត្តកំពង់ចាម នាថ្ងៃទី៩ ខែតុលា ឆ្នាំ២០២២។

-ចែកស្រូវពូជជូនប្រជាពលរដ្ឋរងគ្រោះដោយសារទឹកជំនន់ចំនួន១.៤៤៦គ្រួសារ ក្នុងឃុំចំនួន៦ លើផ្ទៃដី៧៦១ ហិកតា ដែលត្រូវការពូជស្រូវសរុបចំនួន១០៧,៦០៧តោន ក្នុងនោះមួយគ្រួសារទទួលបានពូជស្រូវចន្លោះពី៥០-៦០ គីឡូក្រាម ក្រោមអធិបតីភាពឯកឧត្ដមទេសរដ្ឋមន្ត្រី **គន់ គីម** អនុប្រធានទី១គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ នៅខេត្តកំពង់ចាម នាថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២២។

❋ឯកឧត្ដម **លី សារី** សមាជិកគណៈកម្មការទី៣ព្រឹទ្ធសភាបានអញ្ជើញ៖

-ជួបសំណេះសំណាល សួរសុខទុក្ខប្រជាពលរដ្ឋ និងប្រគល់ផ្ទាំងសូឡាចំនួន៣ផ្ទាំងជូនគណៈគ្រប់គ្រងព្រះវិហារស្រុកទឹកឈូ សម្រាប់បំភ្លឺផ្លូវជូនប្រជាពលរដ្ឋក្នុងការធ្វើ

ដំណើរទៅសាលារៀននាពេលយប់ នៅភូមិត្រពាំងសង្កែ ឃុំត្រពាំងសង្កែ ព្រមទាំងចូលរួមគោរពវិញ្ញាណក្ខន្ធសពប្រជាពលរដ្ឋ នៅភូមិកំពង់សំរោង ឃុំកំពង់សំរោង និងភូមិម៉ាក់ប្រាង្គ ឃុំកំពង់ក្រែង ស្រុកទឹកឈូ ខេត្តកំពត នាថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២២។

-ចូលរួមគោរពវិញ្ញាណក្ខន្ធសពប្រជាពលរដ្ឋ នៅភូមិទទឹងថ្ងៃ សង្កាត់បឹងទូក ក្រុងបូកគោ ខេត្តកំពត នារសៀលថ្ងៃទី២ ខែតុលា ឆ្នាំ២០២២។

-ជួបសំណេះសំណាលជាមួយនឹងក្រុមកីឡាកររាជសីហ៍ និងបានឧបត្ថម្ភថវិកាមួយចំនួនសម្រាប់ទិញសម្លៀកបំពាក់កីឡា ព្រមទាំងចូលរួមគោរពវិញ្ញាណក្ខន្ធសពប្រជាពលរដ្ឋ នៅភូមិម៉ាក់ប្រាង្គ ឃុំកំពង់ក្រែង នៅស្រុកទឹកឈូ ខេត្តកំពត នាថ្ងៃទី១១ ខែតុលា ឆ្នាំ២០២២។

-ជួបសំណេះសំណាល និងសួរសុខទុក្ខប្រជាពលរដ្ឋ នៅឃុំត្រពាំងសង្កែ នៅស្រុកទឹកឈូ ខេត្តកំពត នាថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២២។

-ចូលរួមគោរពវិញ្ញាណក្ខន្ធសពប្រជាពលរដ្ឋ នៅភូមិកំពង់សំរោង ឃុំកំពង់សំរោង ស្រុកទឹកឈូ ខេត្តកំពត នាព្រឹកថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២២។



❋នាព្រឹកថ្ងៃទី១ ខែតុលា ឆ្នាំ២០២២ ឯកឧត្តម **សត ណាឌី** សមាជិកគណៈកម្មការទី៤ព្រឹទ្ធសភា ឯកឧត្តម **ឡៅ ឆន** សមាជិកគណៈកម្មការទី៧ព្រឹទ្ធសភា និងឯកឧត្តម **សួន លន់** សមាជិកគណៈកម្មការទី១០ព្រឹទ្ធសភា និងលោកជំទាវ **ឯម ផលាមុនី** សមាជិកាគណៈកម្មការទី១០ព្រឹទ្ធសភាបានអញ្ជើញចូលរួមពិធីសំណេះសំណាលជាមួយនឹងប្រជាពលរដ្ឋ ដែលបានស្ម័គ្រចិត្តរើលំនៅឋាន និងសំណង់ផ្សេងៗចេញពីតំបន់រមណីយដ្ឋានអង្គរ ក្រោមការគ្រប់គ្រងរបស់អាជ្ញាធរជាតិអប្សរា ចំនួន២.៧៥១គ្រួសារ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅភូមិធម្មជាតិរុនតាឯក ស្រុកបន្ទាយស្រី ខេត្តសៀមរាប។

❋នាថ្ងៃទី១ ខែតុលា ឆ្នាំ២០២២ ឯកឧត្តម **មួង ប៉យ** សមាជិកគណៈកម្មការទី៤ព្រឹទ្ធសភាបានអញ្ជើញជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាឃុំទាំងអស់នៃស្រុកតាវែង ខេត្តរតនគិរី។



❋នាថ្ងៃទី២ ខែតុលា ឆ្នាំ២០២២ លោកជំទាវ **ឃួន ឃុនឌី** សមាជិកាគណៈកម្មការទី៥ព្រឹទ្ធសភាបានអញ្ជើញជួបសំណេះសំណាល និងសួរសុខទុក្ខ ព្រមទាំងនាំយកអំណោយជូនបងប្អូនប្រជាពលរដ្ឋដែលកំពុងជួបការខ្វះខាតជីវភាព រងគ្រោះដោយសារជំនន់ទឹកភ្លៀងចំនួន៦០គ្រួសារ ចំនួន៣ភូមិ ដោយមួយគ្រួសារៗទទួលបាន៖ អង្ករចំនួន២០គីឡូក្រាម មី ត្រីខ ទឹកត្រី ទឹកស៊ីវអ៊ីវ អំបិល ប៊ីចេង ក្រមាចំនួន១ និងថវិកាមួយចំនួន នៅឃុំកំពង់ស្វាយ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ។

❋នាថ្ងៃទី៩ ខែតុលា ឆ្នាំ២០២២ ឯកឧត្តម **ស្រី បេន** សមាជិកគណៈកម្មការទី៧ព្រឹទ្ធសភាបានអញ្ជើញជួបសំណេះសំណាលជាមួយនឹងសមាជិកក្រុមប្រឹក្សាឃុំសឹង្ហ ស្រុកសំរោង ខេត្តតាកែវ។

❋ឯកឧត្តម **ឡៅ ឆន** សមាជិកគណៈកម្មការទី៧ព្រឹទ្ធសភាបានអញ្ជើញ៖

-ចូលរួមកិច្ចប្រជុំស្ដីពី វឌ្ឍនភាពការងារខែកញ្ញា និងទិសដៅការងារខែតុលា ឆ្នាំ២០២២ លើការងារពង្រឹងសន្តិសុខ ភូមិ ឃុំ មានសុវត្ថិភាព ការបង្ក្រាបល្បែងស៊ីសង ការងារផ្ដល់សេវាជូនប្រជាពលរដ្ឋ ការងារចុះផ្សព្វផ្សាយដល់គ្រួសារតាមភូមិ អ្នកដែលបានចុះឈ្មោះបោះឆ្នោតហើយ និងអ្នកទើបគ្រប់អាយុបោះឆ្នោតឱ្យទៅពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតឆ្នាំ២០២៣ ឱ្យបាន

គ្រប់គ្នា។ នៅស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ នាថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២២។



-ចូលរួមពិធីបុណ្យអុំទូកប្រចាំខេត្តឧត្តរមានជ័យ ដើម្បីអបអរសាទរព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក ព្រមទាំងឧបត្ថម្ភថវិកាមួយចំនួនជួយក្នុងកម្មវិធី និងអ្នកអុំទូក ស្ថិតនៅបឹងស្មោរ ខាងមុខសាលាខេត្តឧត្តរមានជ័យ នារសៀលថ្ងៃទី១ ខែតុលា ឆ្នាំ២០២២។



-ចូលរួមអង្គកឋិនទានសាមគ្គីនៅវត្តខ្នាចត្រាច ហៅវត្តសណ្តាន់ ដើម្បីវេរប្រគេនព្រះសង្ឃ ដែលគង់ចាំព្រះវស្សាអស់រយៈពេលមួយត្រីមាស តាមពុទ្ធានុញ្ញាត ព្រមទាំងបច្ច័យ និងទេយ្យវត្ថុមួយចំនួន ដើម្បីរក្សាទុកសម្រាប់ព្រះសង្ឃ និងកសាងវិស័យពុទ្ធសាសនាក្នុងទីវត្តអារាមនៅឃុំពាក់ស្នែង ស្រុកអង្គរធំ ខេត្តសៀមរាប នាថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២១។

❃ឯកឧត្តម **អ៊ឹង លាងហ៊ី** សមាជិកគណៈកម្មការទី៧ព្រឹទ្ធសភាបានអញ្ជើញ៖

-ជាអធិបតីភាពក្នុងកិច្ចប្រជុំជាមួយនឹងក្រុមប្រឹក្សាខេត្ត ស្រុក ឃុំ ដើម្បីពិនិត្យលទ្ធផលការងារខែតុលា និងលើកទិសដៅការងារខែវិច្ឆិកា ឆ្នាំ២០២២ និងចូលរួមគោរព



ព្រះវិញ្ញាណក្ខន្ធព្រះបរមរតនកោដ្ឋ នៅសាលាស្រុកជលគិរី ខេត្តកំពង់ឆ្នាំង នាព្រឹកថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២២។



-ជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាឃុំ ស្មៀនឃុំ ជំនួយការស្មៀន មេប៉ុស្តិ៍នគរបាលរដ្ឋបាល ប្រធានភូមិ ដើម្បីឈ្វេងយល់ពីគ្រោះធម្មជាតិបង្កដោយទឹកទន្លេ ចំពោះជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ និងស្តាប់របាយការណ៍រួមក្នុងមូលដ្ឋាន ព្រមទាំងពិនិត្យផ្ទាល់តាមផ្ទះ និងឧបត្ថម្ភស្បៀងអាហារ ថវិកាមួយចំនួនដល់៦គ្រួសារ ក្នុងឃុំព្រៃគ្រី ដែលជម្លៀសមករស់នៅលើទួលសុវត្ថិភាព នៅសាលាឃុំជលសា ស្រុកជលគីរី ខេត្តកំពង់ឆ្នាំង នារសៀលថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២២។



-នាំយកនូវអំណោយរបស់សម្តេចចៅហ្វាវាំង វរវៀងជ័យ អធិបតីស្រីង្គារ **គង់ សំអុល** ឧបនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រី

ក្រសួងព្រះបរមរាជវាំង ចែកជូនប្រជាពលរដ្ឋ ដែលរងគ្រោះដោយទឹកទន្លេឡើងលិចផ្ទះ ទូទាំងស្រុកជលគីរី សរុបចំនួន ៣៤៣គ្រួសារ ដែលក្នុងមួយគ្រួសារៗទទួលបាន៖ អង្ករ ត្រីខកំប៉ុង មី ទឹកស៊ីអ៊ីវ ទឹកត្រី ថវិកា និងឧបត្ថម្ភថវិកាមួយចំនួនដល់មន្ត្រី ភូមិ ឃុំ ស្រុក នៅសាលាស្រុកជលគីរី ខេត្តកំពង់ឆ្នាំង នាថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២២។



❈នាព្រឹកថ្ងៃទី៣ ខែតុលា ឆ្នាំ២០២២ ឯកឧត្តម **ទេព យុទ្ធី** សមាជិកគណៈកម្មការទី៨ព្រឹទ្ធសភាបានអញ្ជើញចូលរួមពិធីដាំកូនដើមឈើប្រណិតចំនួន៥០០ដើម នៅភ្នំតាម៉ៅ ស្រុកបាទី ខេត្តតាកែវ។

❈នាថ្ងៃទី១ ខែតុលា ឆ្នាំ២០២២ ឯកឧត្តម **សាយ ម៉ូរិន** សមាជិកគណៈកម្មការទី៨ព្រឹទ្ធសភាបានអញ្ជើញជាអធិបតីភាពក្នុងកិច្ចប្រជុំជាមួយនឹងក្រុមប្រឹក្សាឃុំដូនតី ព្រមទាំងចូលរួមក្នុងពិធីសំណេះសំណាល និងពិសាអាហារសាមគ្គីជាមួយនឹងប្រជាពលរដ្ឋ នៅឃុំដូនតីស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ។

❈ឯកឧត្តម **សួន លន់** សមាជិកគណៈកម្មការទី១០ព្រឹទ្ធសភាបានអញ្ជើញ៖

-ជួបសំណេះសំណាល និងនាំយកអំណោយទៅចែកជូនដល់ប្រជាពលរដ្ឋ ដែលមានជីវភាពខ្វះខាតចំនួន៣១គ្រួសារ ព្រមទាំងឧបត្ថម្ភប្រជាពលរដ្ឋក្រីក្រទាំង១៧គ្រួសារ រួមមាន៖ អង្ករ២០គីឡូក្រាម មី១កេស សារុង១ និងថវិកាមួយចំនួន នៅក្នុងឃុំគោកដូង ស្រុកអង្គរជុំ ខេត្តសៀមរាប នាព្រឹកថ្ងៃទី២០ ខែតុលា ឆ្នាំ២០២២។

-ជាកិត្តិយសក្នុងពិធីជំនួបសំណេះសំណាលជាមួយនឹងប្រជាពលរដ្ឋនៅក្នុងតំបន់អភិវឌ្ឍន៍រុនតាឯក ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ស្ថិតនៅភូមិតានី ឃុំរុនតាឯក ស្រុកបន្ទាយស្រី ខេត្តសៀមរាប នាព្រឹកថ្ងៃទី២១ ខែតុលា ឆ្នាំ២០២២។

-ចូលរួមជាកិត្តិយសក្នុងពិធីជួបសំណេះសំណាលជាមួយនឹងប្រជាពលរដ្ឋនៅក្នុងតំបន់អភិវឌ្ឍន៍ពាក់ស្នែង ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅភូមិពាក់ស្នែងថ្មី ឃុំពាក់ស្នែង ស្រុកអង្គរធំ ខេត្តសៀមរាប នាព្រឹកថ្ងៃទី២២ ខែតុលា ឆ្នាំ២០២២។

❈លោកជំទាវ **ឯម ផលាមុនី** សមាជិកាគណៈកម្មការទី១០ព្រឹទ្ធសភាបានអញ្ជើញ៖

-ចុះសួរសុខទុក្ខលោកយាយ **អៀង យ៉ន** ដែលមានអាយុ៨៣ឆ្នាំ និងឧបត្ថម្ភថវិកាមួយចំនួន នៅឃុំអំពិលក្រៅ ភូមិអំបិលក្រៅ ស្រុកស្រីសន្ធរកណ្តាល ខេត្តព្រៃវែង នាព្រឹកថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២២។

-ចូលរួមក្នុងពិធីបុណ្យកឋិនសាមគ្គី និងពិធីអភិសេកព្រះរូបសំណាកព្រះឥន្ទកោសីយ៍ ក្រោមអធិបតីភាពលោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច ដង្ហែទៅកាន់វត្តព្រះឥន្ទកោសីយ៍ ស្ថិតក្នុងភូមិទ្រាំង ឃុំស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប នាថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២២។

-ចុះសួរសុខទុក្ខឧបាសក **ម៉ែន យិន** អាយុ៨៧ឆ្នាំ និងឧបត្ថម្ភថវិកាមួយចំនួន នៅភូមិទ្រាំង សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប នាព្រឹកថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២២៕

# សមាជិក សមាជិកាព្រឹទ្ធសភាចូលរួមក្នុងពិធីផ្សេងៗ



❈នាថ្ងៃទី៦ ខែតុលា ឆ្នាំ២០២២ សមាជិកព្រឹទ្ធសភា ចំនួន៧រូប បានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីបើក អង្គសន្និសីទចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ២០២២ លើ ប្រធានបទ "ការស្ដារឡើងវិញ នៃប្រទេសកម្ពុជា ការអភិវឌ្ឍប្រកបដោយនិរន្តរភាពបន្ទាប់ពីជំងឺកូវីដ-១៩" ក្រោម អធិបតីភាពដ៏ខ្ពង់ខ្ពស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងបិទអង្គពិធីក្រោមអធិបតីភាពឯកឧត្ដមអគ្គបណ្ឌិត សភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅសណ្ឋាគារសុខាភ្នំពេញ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។



❈នាល្ងាចថ្ងៃទី១១ ខែតុលា ឆ្នាំ២០២២ សមាជិក សមាជិកាព្រឹទ្ធសភាចំនួន៩រូប បានអញ្ជើញចូលរួមសន្និសីទ ស្ដីពីការរំលឹកខួប១០០ឆ្នាំ នៃថ្ងៃប្រសូតរបស់ព្រះករុណា ព្រះបាទសម្ដេចព្រះ **នរោត្តម សីហនុ** ព្រះវររាជបិតា ជាតិខ្មែរ "ព្រះបរមរតនកោដ្ឋ" ឧទ្ទេសនាមដោយលោក Olivier de Bernon នាយកសិក្សានៅសាលាបារាំងចុងបូព៌ា នៅវិទ្យាស្ថានបារាំងប្រចាំនៅកម្ពុជា។

❈នាថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២២ សមាជិក សមាជិកា ព្រឹទ្ធសភាចំនួន១១រូប បានអញ្ជើញចូលរួមក្នុងសិក្ខាសាលា ស្ដីពី "តួនាទីសភាក្នុងការងារប្រែប្រួលអាកាសធាតុ" ក្រោម អធិបតីភាពឯកឧត្ដម **សាយ សំអាល់** រដ្ឋមន្ត្រីក្រសួង បរិស្ថាន នៅវិមានរដ្ឋសភា។



❈នាថ្ងៃទី៧ ខែតុលា ឆ្នាំ២០២២ ឯកឧត្ដម **យ៉ង់ សែម** ប្រធានគណៈកម្មការទី១ព្រឹទ្ធសភា និងឯកឧត្ដម **ឈិត គឹមយាត** អនុប្រធានគណៈកម្មការទី៥ព្រឹទ្ធសភាបាន អញ្ជើញចូលរួមប្រជុំត្រៀមរៀបចំមហាសន្និបាតអាយប៉ា លើកទី៤៣ និងកិច្ចប្រជុំទល់មុខគ្នារវាងថ្នាក់ដឹកនាំអាយប៉ា និងប្រមុខដឹកនាំអាស៊ាន ក្រោមអធិបតីភាពឯកឧត្ដមកិត្តិសេដ្ឋាបណ្ឌិត **ជាម យៀប** អនុប្រធានទី១រដ្ឋសភា និង ជាប្រធានគណៈកម្មការរៀបចំមហាសន្និបាតអន្តរសភា អាស៊ានអាយប៉ាលើកទី៤៣ នៅសាលបាយ័ន នៃវិមាន រដ្ឋសភា។




❈នាព្រឹកថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២២ ឯកឧត្ដម **ខា ខេដ្ឋ** ប្រធានគណៈកម្មការទី២ព្រឹទ្ធសភា ឯកឧត្ដមបណ្ឌិត

**ម៉ុង ឬទ្ធី** ប្រធានគណៈកម្មការទី៣ព្រឹទ្ធសភា ឯកឧត្តម **សុខ ឥសាន** ប្រធានគណៈកម្មការទី៤ព្រឹទ្ធសភា ឯកឧត្តម **គង់ សារាជ** ប្រធានគណៈកម្មការទី៩ព្រឹទ្ធសភា និងលោកជំទាវ **ម៉ុំ សណ្ដាប់** លេខាធិការគណៈកម្មការទី៨ព្រឹទ្ធសភាបានអញ្ជើញចូលរួមជាកិត្តិយសក្នុងវេទិកាជាតិអន្តរសាសនា ប្រឆាំងការជួញដូរមនុស្ស និងទេសភាពសម័យទំនើបលើកទី៦ ឆ្នាំ២០២២ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍អន្តរជាតិជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។

❈នារសៀលថ្ងៃទី១០ ខែតុលា ឆ្នាំ២០២២ ឯកឧត្តមបណ្ឌិត **ម៉ុង ឬទ្ធី** ប្រធានគណៈកម្មការទី៣ព្រឹទ្ធសភា និងឯកឧត្តម **ឡាន់ ឆន** លេខាធិការគណៈកម្មការទី១០ព្រឹទ្ធសភាបានអញ្ជើញចូលរួមពិធីបុណ្យកឋិនទាន ដែលផ្ដួចផ្ដើមឡើងដោយសម្ដេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា និងសម្ដេចធម្មវិសុទ្ធវង្សា **សៅ ទី** នៅសង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។



❈នាព្រឹកថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២២ លោកជំទាវ **មាន សំអាន** ប្រធានគណៈកម្មការទី៨ព្រឹទ្ធសភាបានអញ្ជើញដឹកនាំគណៈប្រតិភូគណៈកម្មការទី៨ព្រឹទ្ធសភាចូលរួមគោរពវិញ្ញាណក្ខន្ធសពឧបាសិកា **ទេព សុជានី** កូនស្រីបង្កើតរបស់ឯកឧត្តម **ទេព យុទ្ធី** សមាជិកគណៈកម្មការទី៨ព្រឹទ្ធសភា នៅគេហដ្ឋាន ស្ថិតក្នុងភូមិអូរក្រសារ សង្កាត់អូរក្រសារ ក្រុងកែប ខេត្តកែប។

❈ឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការទី១០ព្រឹទ្ធសភាបាន៖



-រៀបចំពិធីពិសាអាហារសាមគ្គីទទួលស្វាគមន៍គណៈប្រតិភូគណៈកម្មការស៊ើបអង្កេតអំពើពុករលួយ ការប្រព្រឹត្តខុស និងពង្រឹងអភិបាលកិច្ចល្អ នៃព្រឹទ្ធសភាព្រះរាជាណាចក្រថៃឡង់ដ៍ ដឹកនាំដោយឯកឧត្តមឧត្តមនាវីឯក **សិសថាវ៉ាត់ វងស្សុវណ្ណ** ប្រធានគណៈកម្មការ ក្នុងឱកាសដែលឯកឧត្តមដឹកនាំគណៈប្រតិភូមកបំពេញទស្សនកិច្ចនៅព្រះរាជាណាចក្រកម្ពុជា នាល្ងាចថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២២។

-អញ្ជើញចូលរួមក្នុងពិធីបុណ្យកឋិនទានសាមគ្គី ដែលផ្ដួចផ្ដើមឡើងដោយឯកឧត្តមបណ្ឌិត **ថោង ខុន** និងលោកជំទាវ ស្ថិតនៅភូមិគ្រឹះលេខ៣១ ផ្លូវ៣៣៧ សង្កាត់បឹងកក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រមទាំងចូលរួមក្នុងពិធីបុណ្យកឋិនទាន ដែលផ្ដួចផ្ដើមឡើងដោយឯកឧត្តម **ឃួង ស្រេង** និងលោកជំទាវ នៅសាលារាជធានីភ្នំពេញនាថ្ងៃទី២១ ខែតុលា ឆ្នាំ២០២២។



❈នាថ្ងៃទី១២ ខែតុលា ឆ្នាំ២០២២ ឯកឧត្តម **ខៀវ មុត** អនុប្រធានគណៈកម្មការទី១ព្រឹទ្ធសភា និងជាប្រធានក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៥បានអញ្ជើញ

ចូលរួមបុណ្យសពឧបាសិកា **ទេព សុជានី** កូនស្រីបង្កើតរបស់ឯកឧត្តម **ទេព យុទ្ធី** សមាជិកគណៈកម្មការទី៨ព្រឹទ្ធសភា នៅគេហដ្ឋាន ស្ថិតក្នុងភូមិអូរក្រសារ សង្កាត់អូរក្រសារ ក្រុងកែប ខេត្តកែប។

❈នាថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២២ ឯកឧត្តម **ឈិត គីមយាត** អនុប្រធានគណៈកម្មការទី៥ព្រឹទ្ធសភា ឯកឧត្តម **អោយ ខន** អនុប្រធានគណៈកម្មការទី៦ព្រឹទ្ធសភា និងឯកឧត្តម **គិន ណែត** លេខាធិការគណៈកម្មការទី២ព្រឹទ្ធសភាបានអញ្ជើញចូលរួមប្រជុំពិភាក្សាការងារលើគម្រោងថវិកា ដើម្បីត្រៀមរៀបចំមហាសន្និបាតអន្តរសភាអាស៊ានលើកទី៤៣ (AIPA-43) ក្រោមអធិបតីភាពឯកឧត្តម **ឈាង វុន** ប្រធានគណៈកម្មការទី២រដ្ឋសភា និងជាប្រធានអនុគណៈកម្មការហិរញ្ញវត្ថុ ផ្គត់ផ្គង់ និងភស្តុភា នៃមហាសន្និបាតអន្តរសភាអាស៊ាន (អាយប៉ា) លើកទី៤៣ នៅសាលប្រជុំបន្ទាយស្រី វិមានរដ្ឋសភា។



❈នាថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២២ ឯកឧត្តម **អោយ ខន** អនុប្រធានគណៈកម្មការទី៦ព្រឹទ្ធសភាបានអញ្ជើញចូលរួមបុណ្យសពឧបាសិកា **ទេព សុជានី** កូនស្រីបង្កើតរបស់ឯកឧត្តម **ទេព យុទ្ធី** សមាជិកគណៈកម្មការទី៨ព្រឹទ្ធសភា នៅភូមិអូរក្រសារ សង្កាត់អូរក្រសារ ក្រុងកែប ខេត្តកែប។

❈នាថ្ងៃទី១២ ខែតុលា ឆ្នាំ២០២២ ក្រុមសមាជិកាព្រឹទ្ធសភាបានអញ្ជើញចូលរួមកិច្ចប្រជុំកំពូលស្ត្រីអាស៊ានលើកទី២ “ការកសាងអនាគតប្រកបដោយចីរភាព បរិយាបន្ន និងកាន់តែរឹងមាំបំផុសសហគ្រិនភាពរបស់ស្ត្រីក្នុងអាស៊ាន” ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅវិមានសន្តិភាព។






❈នារសៀលថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២២ លោកជំទាវ **ភខ សៅវ៉ែធន** លេខាធិការគណៈកម្មការទី៣ព្រឹទ្ធសភា និងឯកឧត្តម **លី សារី** សមាជិកគណៈកម្មការទី៣ព្រឹទ្ធសភាបានអញ្ជើញចូលរួមក្នុងពិធីបុណ្យខួបគម្រប់៧ថ្ងៃឧបាសិកា **ទេព សុជានី** កូនស្រីបង្កើតរបស់ឯកឧត្តម **ទេព យុទ្ធី** សមាជិកគណៈកម្មការទី៨ព្រឹទ្ធសភា ព្រមទាំងនាំយកសារលិខិតរំលែកទុក្ខ និងថវិការបស់ឯកឧត្តមបណ្ឌិត **ម៉ុង ឫទ្ធី** ប្រធានគណៈកម្មការទី៣ព្រឹទ្ធសភា នៅភូមិអូរក្រសារ សង្កាត់អូរក្រសារ ក្រុងកែប ខេត្តកែប។

❈នាថ្ងៃទី១២ ខែតុលា ឆ្នាំ២០២២ ឯកឧត្តម **សាយ បូរិន** សមាជិកគណៈកម្មការទី៨ព្រឹទ្ធសភាបានអញ្ជើញដង្ហែអង្គកឋិនទានជាមួយសម្ដេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា និងសម្ដេចធម្មវិសុទ្ធវង្សា **សៅ ទី** ទៅវេរប្រគេនព្រះសង្ឃដែលគង់ចាំព្រះវស្សាអស់ត្រីមាសក្នុងពុទ្ធសីមាវត្តចំនួន៩ នៅខេត្តត្បូងឃ្មុំ ខេត្តស្វាយរៀង និងខេត្តព្រៃវែង ដែលប្រារព្ធពិធីនៅវត្តគិរីសុវណ្ណារាម (ហៅវត្តថ្កូវ) ភូមិអន្លង់ជ្រៃ ឃុំកក់ ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ៕

# អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែកញ្ញា និងនព្វមាស ព្រមទាំងកំណត់ទិសដៅការងារបន្ត ឆ្នាំ២០២២




*ឯកឧត្តម អ៊ុំ សារឹទ្ធ (កណ្ដាល) អធិបតីភាពក្នុងកិច្ចប្រជុំ*

នាព្រឹកថ្ងៃទី៦ ខែតុលា ឆ្នាំ២០២២ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានប្រជុំបូកសរុបលទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាប្រចាំខែកញ្ញា និងនព្វមាស ព្រមទាំងលើកទិសដៅការងារបន្ត ឆ្នាំ២០២២ ក្រោមអធិបតីភាព ឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា នៅសាលសិក្ខាសាលាបណ្ណាល័យព្រឹទ្ធសភា ដោយមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចាប់ពីអនុប្រធាននាយកដ្ឋានឡើង។

បន្ទាប់ពីការបញ្ចាំងវីដេអូបូកសរុបលទ្ធផលការងារប្រចាំខែកញ្ញា និងលទ្ធផលការងារប្រចាំនព្វមាស ព្រមទាំងទិសដៅការងារបន្ត ឆ្នាំ២០២២ និងកិច្ចពិភាក្សាផ្លាស់ប្ដូរបទពិសោធន៍ការងារ បញ្ហាប្រឈម និងសំណូមពរ រួចមក ឯកឧត្តម **អ៊ុំ សារឹទ្ធ** បានជម្រាបជូនអង្គប្រជុំបានជ្រាបអំពីសភាពការណ៍អន្តរជាតិ តំបន់ និងសភាពការណ៍ជាតិ ព្រមទាំងធ្វើការបូកសរុបលទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាក្នុងរយៈពេល៩ខែ ឆ្នាំ២០២២ថា អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានអនុវត្តការងារលើមុខងារទាំង៥ សម្រេចបានលទ្ធផលល្អប្រសើរជាងរយៈពេល៩ខែ ឆ្នាំ២០២១។

លទ្ធផលទាំងនេះផ្ដើមចេញពីភាពពធន់ និងភាពឈ្លាសវៃ ព្រមទាំងការចេះបត់បែនរបស់ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា អគ្គនាយកដ្ឋាន នាយកដ្ឋាន ក្នុងការអភិវឌ្ឍសមត្ថភាព និងប្រតិបត្តិការការងាររបស់ខ្លួនផ្អែកលើគោលការណ៍នវានុវត្តន៍ និងស្របតាមការវិវឌ្ឍរីកចម្រើនឥតឈប់ឈរ នៃបច្ចេកវិទ្យាព័ត៌មាន។ ទន្ទឹមគ្នានេះ ដើម្បីទទួលបានលទ្ធផលកាន់តែល្អប្រសើរថែមទៀត អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាបានបើកវគ្គបណ្ដុះបណ្ដាលរយៈពេល៥ថ្ងៃ ស្ដីពីការគ្រប់គ្រងធនធានមនុស្ស ដើម្បីឈ្វេងយល់អំពីសូចនាករលទ្ធផលការងារ និងប្រមូលធាតុចូលក្នុងការកសាងផែនទីបង្ហាញផ្លូវឆ្ពោះទៅសម្រេចឱ្យបានផែនការយុទ្ធសាស្ត្រ ២០២១-២០៣០ សម្រាប់ការអភិវឌ្ឍព្រឹទ្ធសភាឱ្យក្លាយជាសភាទំនើប។

ស្របតាមបរិបទនៃការវិវឌ្ឍថ្មី ជាពិសេសការកាត់បន្ថយថវិកាសម្រាប់ឆ្នាំ២០២២ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានខិតខំពង្រឹងប្រសិទ្ធភាពចំណាយដោយអនុវត្តគោលការណ៍3E's ដើម្បីធានានិរន្តរភាព និងប្រក្រតីភាពការអនុវត្តថវិកាឆ្នាំ២០២២ រហូតដល់បំណាច់ឆ្នាំ ដោយផ្ដោតតែលើការងារអាទិភាពដែលចាំបាច់បំផុត សំខាន់បំផុត និងបន្ទាន់បំផុត។

សម្រាប់ទិសដៅការងារបន្ត ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភាបានកំណត់ឱ្យគ្រប់អង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បន្តផ្ដល់សេវាជូនសមាជិក សមាជិកាព្រឹទ្ធសភាឱ្យបានកាន់តែល្អប្រសើរថែមទៀត និងគ្រប់ជ្រុងជ្រោយលើមុខងារទាំង៥របស់ព្រឹទ្ធសភា ប្រកបដោយគុណភាព ប្រសិទ្ធភាព និងទាន់ពេលវេលា។ ជាមួយគ្នានេះ មន្ត្រីរាជការទាំងអស់ ត្រូវបន្តយកចិត្តទុកដាក់ចូលរួមប្រយុទ្ធប្រឆាំងនឹងការរីករាលដាលនៃជំងឺកូវីដ-១៩ ដោយបន្តអនុវត្តឱ្យបានខ្ជាប់ខ្ជួនតាមវិធានការ និងការណែនាំរបស់ក្រសួងសុខាភិបាលឱ្យបានម៉ត់ចត់ និងល្អប្រសើរ៕

(អត្ថបទ៖ នុត សច្ចៈ រូបភាព៖ គង់ យ៉ារីន)



*ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានចូលរួមប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែកញ្ញា និងនព្វមាស ឆ្នាំ២០២២*

# អគ្គលេខាធិការដ្ឋានព្រឹទ្ធសភារៀបចំពិធីសំណេះសំណាលជាមួយ និវត្តជន និងមន្ត្រីរាជការវ័យចំណាស់




*ឯកឧត្តម ឡោក ឆាយ និងឯកឧត្តម លឹម ប៊ុនហុក*

នាព្រឹកថ្ងៃទី៣ ខែតុលា ឆ្នាំ២០២២ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាបានរៀបចំពិធីសំណេះសំណាលជាមួយនឹងនិវត្តជន និងមន្ត្រីរាជការវ័យចំណាស់ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ក្រោមប្រធានបទ ទិវាមនុស្សចាស់កម្ពុជា និងទិវាមនុស្សចាស់អន្តរជាតិលើកទី២៤ (១ តុលា ឆ្នាំ២០២២)ត្រូវបានកំណត់ថា “មនុស្សវ័យចាស់ជាមរតកដ៏សំខាន់ ក្នុងការអភិវឌ្ឍគ្រួសារ និងសង្គម”។

ពិធីនេះប្រព្រឹត្តទៅក្រោមអធិបតីភាពឯកឧត្តម **ឡោក ឆាយ** អគ្គលេខាធិការស្ដីទីព្រឹទ្ធសភា នៅសាលសិក្ខាសាលាបណ្ណាល័យព្រឹទ្ធសភា ដោយមានការអញ្ជើញចូលរួមពីនិវត្តជន និងមន្ត្រីរាជការវ័យចំណាស់ និងថ្នាក់ដឹកនាំមកពីអង្គភាពចំណុះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាសរុបចំនួន១២០ នាក់។

បន្ទាប់ពីចំណាប់អារម្មណ៍តំណាងនិវត្តជន និងចំណាប់អារម្មណ៍តំណាងមន្ត្រីរាជការវ័យចំណាស់រួចមក ឯកឧត្តម **ឡោក ឆាយ** បានសម្ដែងនូវមនោសញ្ចេតនារីករាយក្រៃលែង ដែលបានចូលរួមក្នុងពិធីសំណេះសំណាលជាមួយនឹងឯកឧត្ដម លោកជំទាវ លោក លោកស្រី ជានិវត្តជន និងមន្ត្រីរាជការវ័យចាស់ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បន្ទាប់ពីអាក់ខានប្រារព្ធពិធីជួបជុំនេះអស់រយៈពេល១ឆ្នាំ (២០២១)ដោយសារបញ្ហាជំងឺកូវីដ-១៩។

ការប្រារព្ធពិធីនាពេលនេះគឺអនុវត្តតាមគោលនយោបាយជាតិស្ដីពី មនុស្សវ័យចាស់ នៃព្រះរាជាណាចក្រកម្ពុជា ២០១៧-២០៣០ និងសេចក្ដីសម្រេចរបស់អង្គការសហប្រជាជាតិ។ ប្រធានបទ នៃទិវាមនុស្សចាស់កម្ពុជា និងទិវាមនុស្សចាស់អន្តរជាតិលើកទី២៤ ថ្ងៃទី១ តុលា ឆ្នាំ២០២២ ត្រូវបានកំណត់ថា “មនុស្សវ័យចាស់ជាមរតកដ៏សំខាន់ក្នុងការអភិវឌ្ឍគ្រួសារ និងសង្គម” សំដៅអំពាវនាវឱ្យសង្គមមានទស្សនៈសកម្មថែមទៀតចំពោះមនុស្សចាស់ ដោយបង្វែរបញ្ហាប្រឈម នៃភាពចាស់ជរារបស់ប្រជាជនទៅជាកាលា-



*ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និវត្តជន និងនិងមន្ត្រីរាជការវ័យចំណាស់ ចូលរួមក្នុងពិធីសំណេះសំណាល*





*ឯកឧត្តម ឡោក ឆាយ និងឯកឧត្តម លីម ប៊ុនហុក ប្រគល់វត្ថុអនុស្សាវរីយដល់និវត្តជន និងមន្ត្រីរាជការវ័យចំណាស់*

នុវត្តភាព និងបង្កើនការយល់ដឹងអំពីសក្ដានុពល នៃសង្គមវ័យចំណាស់ ដើម្បីឱ្យកូនចៅជំនាន់ក្រោយៗទៀត មើលឃើញពីតម្លៃឥតគណនារបស់មនុស្សវ័យចាស់ ។

ឯកឧត្តម **ឡោក ឆាយ** បានបញ្ជាក់ថា ព្រះរាជាណាចក្រកម្ពុជាយើងមានប្រពៃណី ទំនៀមទម្លាប់ដ៏ល្អ កេរមរតកសម្បត្តិវប្បធម៌ដែលសម្បូរបែប និងសមិទ្ធផលទាំងឡាយ ហើយត្រូវបានរក្សាបានគង់វង្សមកដល់សព្វថ្ងៃនេះ គឺកើតចេញពីស្នាដៃ គុណូបការៈ និងការអប់រំប្រៀនប្រដៅ ប្រកបដោយគតិបណ្ឌិតនៃបុព្វបុរស និងចាស់ព្រឹទ្ធាចារ្យរបស់យើង។សង្គមជាតិ នៅតែចាត់ទុកមនុស្សចាស់គឺជាគ្រឹះនៃបញ្ញាញាណ ជាគតិបណ្ឌិត ជាឃ្លាំង នៃបទពិសោធន៍ និងចំណេះដឹង ជាបណ្ណាល័យរស់ ជាសម្បត្តិវប្បធម៌ ជាកេរមរតករបស់ជាតិដ៏ប្រសើរថ្លៃថ្លាបំផុត ហើយពាក្យទូន្មាន និងគំរូល្អរបស់មនុស្សចាស់ ជាផ្នែកមួយសម្រាប់ជាមូលដ្ឋានក្នុងការអប់រំសីលធម៌ ចរិយាធម៌ក្នុងសង្គម ដើម្បីអភិវឌ្ឍជាតិប្រកបដោយចីរភាព និងសមធម៌។ ហេតុនេះការគោរព និងការដឹងគុណមនុស្សវ័យចាស់ និងនិវត្តជន គឺជាសីលធម៌ និងប្រពៃណីដ៏ល្អរបស់ខ្មែរយើងតាំងពីបរមបុរាណមក។

ក្នុងនាមអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងក្នុងនាមឯកឧត្តមផ្ទាល់ ឯកឧត្តម **ឡោក ឆាយ** បានថ្លែងអំណរគុណ ដល់និវត្តជន និងមន្ត្រីរាជការវ័យចំណាស់ ព្រមទាំងមន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានទាំងអស់ ដែលបានរួមចំណែក និងកំពុងតែបំពេញកិច្ចការងារលើគ្រប់វិស័យបម្រើព្រឹទ្ធសភាអស់ពីកម្លាំងកាយចិត្ត ក្នុងន័យបុព្វហេតុជាតិមាតុភូមិ។

(អត្ថបទ៖ នុត សច្ចៈ រូបភាព៖ គង់ យ៉ារីន)



*ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ថតរូបអនុស្សាវរីយ៍ជាមួយនិវត្តជន និងមន្ត្រីរាជការវ័យចំណាស់*

# សកម្មភាពថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចូលរួមកិច្ចប្រជុំ និងពិធីផ្សេងៗ

❈នាព្រឹកថ្ងៃទី១២ ខែតុលា ឆ្នាំ២០២២ ឯកឧត្តម **អ៊ុំ សារីទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា បានដឹកនាំកិច្ចប្រជុំត្រួតពិនិត្យ និងពិភាក្សាការងារសំខាន់ៗរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងបញ្ហាផ្សេងៗ ព្រមទាំងលើកទិសដៅការងារសម្រាប់អនុវត្តបន្ត នៅបន្ទប់ពិសេសកណ្ដាល វិមានព្រឹទ្ធសភា។



❈នាព្រឹកថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២២ ឯកឧត្តម **អ៊ុំ សារីទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា បានទទួលជួបជាមួយនឹងអ្នកស្រី **ឃុ ម៉ូរី** នាយកប្រតិបត្តិក្រុមហ៊ុនថៃឡឺន អ៊ិចសឹឡិន ឌីវេឡុបមិន ជាតនើរ ដើម្បីពិភាក្សាអំពីការរៀបចំវគ្គបណ្ដុះបណ្ដាលស្ដីពី វិធីសាស្ត្របង្កើតសូចនាករគន្លឹះវាស់វែងលទ្ធផលការងារ Key Performance Indicators (KPIs) នៅបន្ទប់ពិសេសកណ្ដាល វិមានព្រឹទ្ធសភា។



❈នាថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២២ នៅខេត្តសៀមរាប ឯកឧត្តម **អ៊ុំ សារីទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញពិសាអាហារពេលល្ងាចជាមួយនឹងមន្ត្រីរដ្ឋបាលជាន់ខ្ពស់មកពីសភាបារាំង នៅសណ្ឋាគារ Royal Angkor Resort។



❈នារសៀលថ្ងៃទី២០ ខែតុលា ឆ្នាំ២០២២ នៅខេត្តសៀមរាប ឯកឧត្តម **អ៊ុំ សារីទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំក្រុមប្រឹក្សាពិគ្រោះយោបល់ជាមួយនឹងអគ្គលេខាធិការនៃសភានានាដែលជាសមាជិកអាយប៉ា។



# សកម្មភាពថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចូលរួមកិច្ចប្រជុំ និងពិធីផ្សេងៗ

❈នាព្រឹកថ្ងៃទី២០ ខែតុលា ឆ្នាំ២០២២ ឯកឧត្តម **អ៊ុំ សារិទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា បានអនុញ្ញាតឱ្យលោក Jean Lestienne ទីប្រឹក្សាតំណាងឱ្យសហគមន៍បារាំងនៅឯនាយសមុទ្រ និងលោក Charles Limousse ទទួលបន្ទុកផ្នែកតួរ្យតន្ត្រី ជួបសំដែងការគួរសម នៅខេត្តសៀមរាប។



❈នារសៀលថ្ងៃទី១១ ខែតុលា ឆ្នាំ២០២២ ឯកឧត្តម **ឡោក ឆាយ** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញជាអធិបតីភាពក្នុងពិធីបិទវគ្គបណ្ដុះបណ្ដាលស្ដីពី ការចែករំលែកបទពិសោធន៍លើការងារព័ត៌មាន និងការផ្សព្វផ្សាយនៅក្នុងបរិបទឌីជីថល នៅសាលសិក្ខាសាលាខាងជើង វិមានព្រឹទ្ធសភា។



❈នាព្រឹកថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២២ ឯកឧត្តម **ឡោក ឆាយ** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញជាអធិបតីភាពក្នុងកិច្ចប្រជុំពិនិត្យ ពិភាក្សាអំពី បែបបទ និងកម្មវិធីសម្រាប់ការអនុវត្តចំពោះការងារជំរឿន ដែលនឹងត្រូវអនុវត្តក្នុងត្រីមាសទី៤ ឆ្នាំ២០២២ នៅសាលប្រជុំពិសេសជាន់ក្រោម វិមានព្រឹទ្ធសភា។



❈នារសៀលថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២២ ឯកឧត្តម **ឡោក ឆាយ** អគ្គលេខាធិការស្ដីទីព្រឹទ្ធសភា បានដឹកនាំកិច្ចប្រជុំការងារសំខាន់ៗរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងទិសដៅការងារខាងមុខ នៅសាលប្រជុំពិសេសជាន់ក្រោម វិមានព្រឹទ្ធសភា។



# សកម្មភាពថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចូលរួមកិច្ចប្រជុំ និងពិធីផ្សេងៗ

❈នារសៀលថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២២ ឯកឧត្តម **ឈឹម ព្រះខ័ន** អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានទទួលជួបពិភាក្សាការងារជាមួយនឹងលោក Wu Chuanbing ទីប្រឹក្សាស្ថានទូត នៃសាធារណរដ្ឋប្រជាមានិតចិន ប្រចាំព្រះរាជាណាចក្រកម្ពុជា ស្ដីពីការបង្កើនទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការរវាងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងស្ថានទូតនៃសាធារណរដ្ឋប្រជាមានិតចិនប្រចាំកម្ពុជា នៅបណ្ណាល័យព្រឹទ្ធសភា។





❈នាព្រឹកថ្ងៃចន្ទ ទី២៦ ខែកញ្ញា ឆ្នាំ២០២២ លោកជំទាវ **សាយ ចាន់ណាក់** នាយិការងខុទ្ទកាល័យសម្ដេចប្រធានព្រឹទ្ធសភា បានអញ្ជើញនាំយកអំណោយរបស់សម្ដេចវិបុលសេនាភក្ដី និងលោកជំទាវ ចែកជូនកុមារ នៅអង្គការកុមារកំព្រាចំនួន២ គឺៈ អង្គការបណ្ដុះបណ្ដាល និងថែរក្សាកុមារកំព្រា និងអង្គការកុមារកំព្រាភូមិថៃ មានទីតាំងស្ថិតក្នុងឃុំត្រែងត្រយឹង ខេត្តកំពង់ស្ពឺ។

❈នាព្រឹកថ្ងៃអាទិត្យ ទី២ ខែតុលា ឆ្នាំ២០២២ ឯកឧត្តម **ម៉ម ឡេងយ៉ានី** នាយករងខុទ្ទកាល័យសម្ដេចប្រធានព្រឹទ្ធសភា បានអញ្ជើញនាំយកសារលិខិតរំលែកទុក្ខរបស់សម្ដេចប្រធានព្រឹទ្ធសភា និងគោរពវិញ្ញាណក្ខន្ធសពមហាឧបាសិកា **ទឹម អ៊ីន** ជំនួយការសម្ដេចប្រធានព្រឹទ្ធសភា នៅគេហដ្ឋានស្ថិតក្នុងទីរួមខេត្តកំពង់ស្ពឺ។



❈នារសៀលថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២២ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា សហការជាមួយនឹងសមាគមអ្នកស្រាវជ្រាវវឌ្ឍភាពកម្ពុជា-ចិន រៀបចំពិធីបាឋកថាឈ្វេងយល់អំពីការបង្កើតសាធារណរដ្ឋប្រជាមានិតចិន និងការចែករំលែកភាពគំរូ នៃភូមិមិត្តភាពកម្ពុជា-ចិន នៅសាលសិក្ខាសាលាបណ្ណាល័យព្រឹទ្ធសភា៕



